# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ សៅ ស្រ៊ុន ភេទប្រុស អាយុ៧៣ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ អ្នកទោស
## មុខងារបច្ចុប្បន្នៈ ចូលនិវត្តន៍
## សព្វថ្ងៃរស់នៅភូមិស្មោរ សង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ
## ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និងឡុង ដានី

ដារ៉ា ៖ អ៊ីចឹងខ្ញុំសុំចាប់ផ្ដើមដំបូង ចង់ស្គាល់ឈ្មោះអ៊ុំបំពេញ?

ស្រ៊ុន ៖ សៅ ស្រ៊ុន ។

ដារ៉ា ៖ សៅ ស្រ៊ុន អ៊ុំនេះ?

ស្រ៊ុន ៖ បាទ!

ដារ៉ា ៖ ហើយអ៊ុំអាយុប៉ុន្មានហើយឆ្នាំហ្នឹង?

ស្រ៊ុន ៖ ៧៣អីអាម៉ាក ៧៣អី ខ្ញុំមិនសូវរាប់ផង (សើច) ។

ដារ៉ា ៖ អ៊ុំកើតឆ្នាំណាអ៊ុំ?

អ្នកជិតខាង ៖ តាគាត់៧២ ។

ស្រ៊ុនៈ ឪរីវីមីនិកសង់ក្រុងអង, ១០ ខែ៤ ៤១ ។

ដារ៉ា ៖ ៤១នេះ?

ស្រ៊ុន ៖ បូកចេញឃើញហើយ ។

ដារ៉ា ៖ អ៊ុំមានកូនចៅប៉ុន្មាននាក់អ៊ុំ?

ស្រ៊ុន ៖ ខ្ញុំ៩ ស្លាប់អស់៣ ខ្ញុំ១២នោះ ។

ដារ៉ា ៖ កូនចៅអ៊ុំ?

ស្រ៊ុន ៖ បាទ!

ដារ៉ា ៖ អូ! កូនចៅច្រើន?

ស្រ៊ុន ៖ តែកូនទេ ចៅៗរាប់ផ្សេងទៀត តែគិតតែកូន វាស្លាប់អស់៣ នៅ៨ ។

ដារ៉ា ៖ ហើយស្រុកកំណើតរបស់អ៊ុំ? ស្រុកកំណើតកើតជា?

ស្រ៊ុន ៖ ស្រុកកំណើតខ្ញុំកន្លែងនេះហ្នឹងម៉ង ។

ដារ៉ា ៖ នៅ?

ស៊ឹុន ៖ ស្រែខ្វាវជាមួយប្អូនខ្ញុំស្រុកកំណើតខ្ញុំ ។

ដារ៉ា ៖ ស្រុកស្រែខ្វាវ ឃុំ?

ស៊ឹុន ៖ ដាងទង ។

ដារ៉ា ៖ ស្រុកត្រាំកក់ ខេត្តតាកែវ ។

ស៊ឹុន ៖ បាទ!

ដារ៉ា ៖ កាលពីអ៊ំនៅពីក្មេង អ៊ំបានរៀនសូត្រនៅក្នុងភូមិព្រៃកប្បាស?

ស៊ឹុន ៖ ខ្ញុំរៀនសូត្រនៅសាលាវត្តអង្គរការហ្នឹងម៉ង អង្គរការហ្នឹង ឌូ, អុង ខ្ញុំប្រឡងជាប់ស៊ឺការ ឌី ទីព្រឹមេទ័រកំភ្លីមេទ័រ ប្រឡងនៅអង្គតាសោម សង់អង្គតាសោម ។

ដារ៉ា ៖ នៅភូមិនេះគេហៅភូមិអីអ៊ំ?

ស៊ឹុន ៖ គេហៅភូមិស្នោរផលូវ ។

ដារ៉ា ៖ អ៊ំរស់នៅក្នុងភូមិស្នោរ?

ស៊ឹុន ៖ បាទ!

ដារ៉ា ៖ ឃុំអីគេអ៊ំ?

ស៊ឹុន ៖ ឃុំរការក្នុង ។

ដារ៉ា ៖ ស្រុក?

ស៊ឹុន ៖ ស្រុកដូនកែវ ។

ដារ៉ា ៖ ខេត្តតាកែវ ។

ស៊ឹុន ៖ បាទ!

ដារ៉ា ៖ អ៊ំពត គាត់ប្រាប់ថា គាត់ចាំអត់ច្បាស់ដែរឃុំ គាត់ថាភូមិរការក្រៅ ដល់ពេលសួរចង់ចេញទៅខាងនោះវិញ ។

ស៊ឹុន ៖ រការក្រៅគេទើបតែបែងចែកផលូវអូនណា៎ គាត់អត់ដឹងដែរ ។

ដារ៉ា ៖ អីចឹងរការក្នុង ។ ពេលអ៊ំរៀនសូត្រអីនៅឃុំស្រែខ្វាវហ្នឹង រៀនរហូតមកដល់ឆ្នាំណាទើបអ៊ំផ្លាស់ទៅនៅភ្នំពេញ នៅអី?

ស៊ឹុន ៖ ខ្ញុំជាប់ស៊ឺការឆ្នាំ៥៨-៥៩ ខ្ញុំរៀនប្រ៊ីវេនៅរាជស័ព្ទគេ ៦០ខ្ញុំចេញទៅភ្នំពេញ ។

ដារ៉ា ៖ ឆ្នាំ៦០នោះអ៊ំ?

ស៊ឹុន ៖ បាទ!

ដារ៉ា ៖ ហើយទៅភ្នំពេញអ៊ំធ្វើការងារ?

ស្រ៊ុន ៖ ធ្វើសាលារៀនជំទប់ៗលេខ៣ នៅសាលាសន្កាត់លេខ៦ ខាងត្បូងវិមានឯករាជ្យរាល់ថ្ងៃ ឥលូវហ្នឹងគេដាក់មន្ទីរពេទ្យអូនណាំ ខ្ញុំឃើញនៅសិតថ្នល់ ។

ដារ៉ា ៖ អូ៎!កន្លែង ។

ស្រ៊ុន ៖ ហ្នឹងហើយ ។

ដារ៉ា ៖ មន្ទីរពេទ្យរាល់ថ្ងៃជាកាកបាទក្រហមហ្នឹង?

ស្រ៊ុន ៖ ហ្នឹងហើយជាកន្លែងខ្ញុំ ។

ដារ៉ា ៖ កន្លែងហ្នឹងជា?

ស្រ៊ុន ៖ សាលាសន្កាត់លេខ៦ពីដើម ។

ដារ៉ា ៖ សន្កាត់លេខ៦?

ស្រ៊ុន ៖ បាទ! ឃើញចេះតែស្រណោះ ។

ដារ៉ា ៖ ហើយអ៊ំជាជំទប់ទីប៉ុន្មាន?

ស្រ៊ុន ៖ ជំទប់ទី៣អូន ។

ដារ៉ា ៖ ជំទប់ទី៣ សន្កាត់លេខ៦?

ស្រ៊ុន ៖ បាទ!

ដារ៉ា ៖ ហើយដល់ឆ្នាំណាទៅអ៊ំ?

ស្រ៊ុន ៖ ដល់៧៥បែកអូន ។

ដារ៉ា ៖ ទាល់តែដល់៧៥ម៉ង?

ស្រ៊ុន ៖ បាទ! បែក ។

ដារ៉ា ៖ អីចឹងពេលដែលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ អ៊ំនៅហ្នឹងហេ៎? នៅក្នុងទីក្រុងភ្នំពេញ?

ស្រ៊ុន ៖ នៅកន្លែងហ្នឹង ប៉ុន្តែផ្ទះដែលខ្ញុំស្នាក់នៅក្រោយពេទ្យកាលម៉ែត្រ ហៅម្តុំបឹងកក់ហ្នឹង ហើយគេបាញ់គ្នាក្បាលថ្នល់ ចូលដល់ដំបូងក្បាលថ្នល់ ហ្នឹង៧៥ក្អួយណាំ ។

ដារ៉ា ៖ ហើយអ៊ំឃើញសភាពយ៉ាងម៉េចដែរ ពេលដែលខ្មែរក្រហមចូលដំបូងបង្អស់នៅក្នុងទីក្រុងភ្នំពេញ?

ស្រ៊ុន ៖ ខ្ញុំអត់បានឃើញកងទ័ពហ្នឹងទេ លឺសូរតែកាំភ្លើងគេ ណាំក្អួយណាំ ។ លឺសូរតែកាំភ្លើងទេ រួចដល់ខ្ញុំក៏វេចខោអាវបាន២បាវយកមកផ្ញើរលោកវត្តស្រះចក ។

ដារ៉ា ៖ ថ្ងៃ១៧ហ្នឹងតែម្តង?

ស្រ៊ុន ៖ បាទ!ៗ ផ្ញើរនៅហ្នឹង វត្តស្រះចក ហើយគេថាគេមកចេញ ឲ្យគេចេញទៅណាំ ហើយខ្ញុំប្រវត្តិសាស្រ្ត វាមិនដែលគេរើហើយគេឲ្យចេញអីចឹង យ៉ាងច្រើនគេឲ្យក្រាប ឲ្យចៀសគ្រាប់

អ៊ីចឹង ក្នុយណាំ ដល់ខ្ញុំនៅចាំប្រហែលជា២ថ្ងៃ ៣ថ្ងៃ បានថាផ្សារថ្មីអីគេស្ងាត់អស់ហើយ គេចេញទៅអស់ ខ្ញុំនៅក្រោយពេទ្យកាល់ម៉ែត្រ ខ្ញុំចេញក្រោយគេណាំក្នុយ ចេញក្រោយគេណាំ ចេញក្រោយគេខ្ញុំចាក់ទៅដែង ចេញក្រោយពេទ្យកាល់ម៉ែត្រទៅដល់ទួលគោកមកលិចមកពោធិ៍ចិនតុងដើម្បីវៀងមកតាកែវ គេអត់បានទេ ព្រោះពួកហ្នឹងវៃចែកមុខសញ្ញាគ្នា ចូលដល់ណាយកប្រជាជនដល់ហ្នឹង ខ្ញុំទៅអីចឹងទៅតាំងគោក វែករហូតដល់តាំងគោកនោះ ។

ដារ៉ា ៖ តាំងគោកហ្នឹងចង់ទៅដល់ផ្លូវទៅកំពង់ធំនោះវិញ?

ស្រ៊ុន ៖ បាទ! កំពង់ធំហួសស្គន់ ហួសផ្លូវបំបែកទៅកំពង់ចាម ទៅដល់កំពង់ធំអនុវិទ្យាល័យតាំងគោក ។

ដារ៉ា ៖ ដើរទៅដល់ហ្នឹង?

ស្រ៊ុន ៖ ដើរ ខ្ញុំវែក ហើយនែក ដល់ហើយទៅដូចថាសណ្ដានចិត្តល្អ ទៅនៅភូមិសំពងជ័យ១ អត់ទាន់ទៅដល់នោះភ្លាមទេ នៅខាងលិចផ្លូវទេ អនុវិទ្យាល័យតាំងគោកនៅខាងលិចផ្លូវ ខ្ញុំនៅតាមភូមិគេហ្នឹង ភូមិសំពងជ័យ រួចដល់ប្រហែលជាបានមួយអាទិត្យ ប្រជាជនទាំងអស់ អ្នកផ្ទះដែលខ្ញុំនៅហ្នឹង ដូចខ្ញុំឲ្យប្រពន្ធខ្ញុំឲ្យខោ ឲ្យអាវទៅ ហើយគ្នាកំពុងអត់កាលហ្នឹង ឲ្យទៅដូចថាមានចិត្តធម៌ គ្រាន់តែប្រាប់ថាឥលូវ ថ្ងៃហ្នឹងរទេះ៣៣, ៣៣រទេះនេះ មកឈប់នៅមុខផ្ទះដើម្បីដឹកអ្នកថ្មី ទៅនៅស្ពឹចម្ការលើ ស្ពឹតាប្រេង អាហ្នឹងត្រូវឆ្លងផ្លូវ កំពង់ធំ-សៀមរាបហ្នឹងណាំ ហើយថា នៅឲ្យស្ងៀមទៅគ្រាន់តែរៀបចំទៅបានហើយ ហើយចាំគេទៅអស់ចាំយើងវែកតាមក្រោយគេទៅ គេឲ្យយោបល់អូនណាំ កាលណាទៅផុតអីចឹងដល់ផ្លូវជាតិយើងមកវិញមកវែកតាមផ្លូវជាតិមកវិញមក តាមផ្លូវជាតិមក វែកមក ខ្ញុំមកដេកនៅបាធាយអូន ដំណើរលឿនណាស់ ដំណើរអត់សំបុត្រទៅ ដំណើរលឿនខ្លាចគេតាម ដេកហ្នឹងតែមួយយប់ ឆ្លង១ឆ្លងមកដល់អង្គតាសោមនេះ ។

ដារ៉ា ៖ ឆ្លងដល់មកដល់អង្គតាសោម?

ស្រ៊ុន ៖ បាទ!

ដារ៉ា ៖ ប៉ុន្មានអាទិត្យ ប៉ុន្មានខែទៅបានមកដល់? ពីថ្ងៃបែកភ្នំពេញ?

ស្រ៊ុន ៖ ពីបែកភ្នំពេញហ៎?

ដារ៉ា ៖ បើគិតពីថ្ងៃបែកភ្នំពេញ ថ្ងៃ១៧ មេសា នោះអ៊ំ ហើយទំរាំមកដល់អង្គតាសោមអ៊ំត្រូវធ្វើដំណើរប៉ុន្មានថ្ងៃ ប៉ុន្មានអាទិត្យ ប៉ុន្មានខែទៅ?

ស្រ៊ុន ៖ ទៅនៅនោះប្រហែល២អាទិត្យ គេបញ្ជូនទៅនោះទៀត ហើយខ្ញុំរត់មកពេលហ្នឹង មកពេលមក ពេលបែកទំរាំមកដល់តាកែវហ្នឹង១៥ថ្ងៃអីចឹងអូន ។

ដារ៉ា ៈ អ៊ីចឹងថយក្រោយបន្តិចដែរ កន្លែងនៅពេលដែលខ្មែរក្រហមចូលដល់ភ្នំពេញហ្នឹង អ៊ំមិនថាផ្ទះអ៊ំនៅកន្លែងបឹងកក់ ។

ស្រ៊ុន ៈ ក្រោយពេទ្យកាល់ម៉ែត្រ ក្បែរបឹងកក់ ។

ដារ៉ា ៈ ក្រោយពេទ្យកាល់ម៉ែត្រ វាមិនជាប់នឹងស្ថានទូតបារាំង ។

ស្រ៊ុន ៈ ខាងលិចស្ថានទូតបារាំង ។

ដារ៉ា ៈ ខាងលិចស្ថានទូតបារាំងហ្នឹង អ៊ីចឹងអ៊ំមានឃើញសភាពយ៉ាងម៉េចដែរ នៅជុំវិញបរិវេណស្ថានទូតបារាំង ពេលដែលខ្មែរក្រហមចូល?

ស្រ៊ុន ៈ ដូចជាស្ងាត់អត់មានឃើញអី តែពេលដែលខ្ញុំយកខោអាវមកផ្ញើរនឹងលោកវត្តស្រះចកហ្នឹង ខ្ញុំឃើញកងទ័ពមកពីជើង លើកទង់ជ័យស ថាសន្តិភាពហើយៗ ឃើញហ្នឹងឃើញដាក់ស្ពែង ខ្ញុំឈរមើលដែរ តែប៉ុណ្ណឹងទេ ។ បាទៗ ។

ដារ៉ា ៈ អ៊ីចឹងពេលមកដល់អន្តតាសោមហើយអ៊ំ?

ស្រ៊ុន ៈ ដល់អន្តតាសោមខ្ញុំវែកទៅលិចទៀតអូន ។

ដារ៉ា ៈ វែកទៅលិចអន្តតាសោម?

ស្រ៊ុន ៈ បាទ! ទៅអង្គរការវែក ។

ដារ៉ា ៈ ឆ្ពោះទៅ?

ស្រ៊ុន ៈ ទៅអង្គរការហ្នឹង វែកទៅតែម្តង វែកនិយាយពីពីងពង់ខ្ញុំមួយ សំរាប់ទល់បង្ហួចខ្ញុំវែកអាហ្នឹង ខ្លាចបាក់ដល់ហើយអត់អី ធ្មើងដងវែក វែកអាហ្នឹង អង្គរការវែក ។

ដារ៉ា ៈ វែកទាល់តែដល់អង្គរការ?

ស្រ៊ុន ៈ បាទ!

ដារ៉ា ៈ ដល់អង្គរការអ៊ំ?

ស្រ៊ុន ៈ ចូលផ្ទះ ។

ដារ៉ា ៈ ចូលផ្ទះអ៊ុំ?

ស្រ៊ុន ៈ ចូលផ្ទះ មើលផ្ទះខ្ញុំមិនចង់ស្គាល់ទៀតចុះតាំងពី ។

ដារ៉ា ៈ ផ្ទះអ៊ំពតហ្នឹង?

ស្រ៊ុន ៈ ខាងត្បូងហ្នឹង ម៉្តុំប្រទ្បាយៗមកកើតអូន ផ្ទះកំណើតម្តាយខ្ញុំៗ នៅត្បូងប៉ុន្តែគាត់ទៅមានគ្រួសារនៅនោះ ហើយបានកើតជាខ្ញុំនៅនោះអូនណាស់អ៊ីចឹង ផ្ទះម្តាយខ្ញុំនៅកោះក្រសាំង ឃុំរការក្រៅនេះ បាទៗ ឃុំរការក្រៅ ។

ដារ៉ា ៈ ពេលទៅដល់ភូមិម៉េចទៅ មានរឿងរ៉ាវអីកើតឡើង?

ស្រ៊ុន ៖ ទៅដល់ភូមិខ្ញុំទៅបានពាយប់តាំ គេថាឲ្យទៅរៀនសូត្រណាំ រៀនសូត្រហ្នឹងខ្ញុំ ហ៎!មិនមែនទៅរៀនសូត្រទេ គេឲ្យទៅជួយសែងគ្រែនៅវិមានសព នៅកន្លែងពេទ្យហ្នឹង ពេទ្យអគ្គិសនីផ្លូវទៅព្រៃស្វា ផ្លូវទៅផ្ទះប្អូនខ្ញុំហ្នឹង ផ្លូវកាច់ជ្រុងហ្នឹង កន្លែងហ្នឹងកាលដែលខ្ញុំទៅនៅបាន២យប់ គេកប់សព ថាមន្ទីរសពៗហ្នឹង ៣៣អី ៣៣ស្នូរអូនៗ

ដារ៉ា ៖ ៣៣ផ្នូរៗ

ស្រ៊ុន ៖ ៣៣ផ្នូរខ្មោច ស្លាប់នៅណាយកទៅហ្នឹង អីណាទៅយកដាក់ហ្នឹង កន្ទ័ពប៉ុលពតអីគេហ្នឹង ហើយខ្ញុំអ្នកខ្លាចខ្មោច ពេលដែលគេហៅខ្ញុំពីផ្ទះទៅ គេឲ្យខ្ញុំឈប់ចាំនៅកាច់ជ្រុងហ្នឹង បាទ!

ដារ៉ា ៖ ហើយម៉េចទៀតទៅអ៊ំ?

ស្រ៊ុន ៖ ឲ្យឈប់ចាំកាច់ជ្រុងហ្នឹង ហើយគេឆ្លងព្រែក អាព្រែកនឹងផ្សារអគ្គិសនីហ្នឹង ទៅខាងត្បូង ព្រោះមន្ទីរគេនៅហ្នឹងអូនណាំ មន្ទីរគេ ហើយឲ្យខ្ញុំអង្គុយចាំម្នាក់ឯងៗ

ដារ៉ា ៖ មន្ទីរអីគេហ្នឹង?

ស្រ៊ុន ៖ មន្ទីរថាប៉ុលពតវាដើរធ្វើការ ប៉ុន្តែមន្ទីរឈ្លប មន្ទីរគេអីនៅហ្នឹង សំរាប់មន្ទីរសហករណ៍សំរាប់ដឹកខោអាវ ដឹកអីចែកតាមឃុំតាមអីគេ កាលជំនាន់ប៉ុលពតៗ ខ្ញុំអង្គុយចាំហ្នឹង ដល់ខ្ញុំអង្គុយចាំយូរគេមកហៅ ហៅទៅហ្នឹងៗ

ដារ៉ា ៖ ហៅទៅមន្ទីរ?

ស្រ៊ុន ៖ បាទ!

ដារ៉ា ៖ ហៅពីកន្លែង?

ស្រ៊ុន ៖ ខ្ញុំអង្គុយខាងជើងភ្លឺហ្នឹង ខាងជើងប្រឡាយ ទៅដល់មន្ទីរ គេថាគោះទៅទៀត គេគ្រាន់តែថាអីចឹងទេណាំស់ៗ

ដារ៉ា ៖ ពីណាមកហៅអ៊ំ?

ស្រ៊ុន ៖ ប្រធានភូមិមួយនៅខាងលិចផ្ទះខ្ញុំនេះៗ

ដារ៉ា ៖ គាត់ឈ្មោះអី?

ស្រ៊ុន ៖ ប៉ែនៗ

ដារ៉ា ៖ អូ! ឈ្មោះ ប៉ែនៗ

ស្រ៊ុន ៖ បាទ! ប្រធានភូមិហ្នឹង រួចដល់ហើយឈ្លប២នាក់ បណ្ដើរខ្ញុំទៅត្រពាំងធំ កាំភ្លើង២ដើម ខ្ញុំមើល ហើយខ្ញុំទៅអត់មានក្រមារមានអី មានតែសារ៉ុងណាំអូន សារ៉ុងប្រពន្ធៗ

ដារ៉ា ៖ អត់មានអាវទេ?

ស្រ៊ុន ៖ អត់ អាវអត់ទេ ទៅដល់ផ្លូវទៅត្រពាំងកកោះ ដល់ត្រពាំងធំមានផ្លូវមួយទៅត្រពាំងកកោះ នេះហៅត្រពាំងកកោះ នៅចាំកន្លែងហ្នឹង កន្លែងហ្នឹងបើតាមនេះគេហៅផ្ទះរបស់ ប៉ុជឹម ហ្នឹង

ដារ៉ា ៖ ផ្ទះរបស់តាជឹម?

ស្រ៊ុន ៖ បាទ! ជឹម គណៈស្រុក ដែលរៀនជាមួយខ្ញុំហ្នឹងណាស់ ។

ដារ៉ា ៖ រៀនជាមួយគ្នាទៀត តាជឹម ហ្នឹង?

ស្រ៊ុន ៖ រៀនជាមួយគ្នា ។

ដារ៉ា ៖ ហើយម៉េចទៀតទៅអ៊ី?

ស្រ៊ុន ៖ ទៅដល់ហ្នឹងដេកហ្នឹងមួយយប់ ដេកមួយយប់ស្អែកឡើងគេឲ្យទៅមន្ទីរ២០៤ បណ្ដើរអាផ្លូវក្រោយវត្តត្រពាំងធំទៅអ៊ីចឹងទៀត ទៅដល់មន្ទីរហ្នឹង គេអត់ឲ្យនៅហ្នឹងមន្ទីរណា គេឲ្យទៅនៅរោងមួយវែង គ្នាប្រហែល៣០នាក់ទេរោងវែងហ្នឹង នៅខាងចេះ ដំបូលចេះអត់មានប្រក់ ដំបូលអត់មានប្រក់ស្លឹកត្នោតទេ គេប្រក់ស្លឹកដូងយើងធំៗ គេដេរ ខ្ញុំអង្គុយចេះតែមើលដល់អាមួយធំជាងហ្នឹងបន្តិចទេ គេថាឯងអង្គុយកុំដើរទៅណា អង្គុយឲ្យស្ងៀម ប្រាប់ខ្ញុំអ៊ីចឹង ។

ដារ៉ា ៖ អាក្មេងហ្នឹងនិយាយអ៊ីចឹង?

ស្រ៊ុន ៖ អាក្មេងធំប៉ុណ្ណឹងតិច ថាឯងកុំដើរទៅណាអង្គុយលើហ្នឹង ហើយបានអាមួយដែលជាប់ទោសជាមួយខ្ញុំហ្នឹង សមមិត្តអើយគាត់ចាស់ហើយកុំថាឲ្យគាត់អ៊ីចឹង អាហ្នឹងស្ទុះមកវ៉ៃ វ៉ៃ៣-៤ កំផ្លៀង វ៉ៃដាក់អ្នកដែលប្រាប់ហ្នឹង ... អង្គុយចាំយូរបន្តិច វាថាហ៎! ដូសបាយ គេធ្វើរោងដូសបាយហ្នឹង ខ្ទះធំប្រហែលជា៣កំប៉ុងទេមួយខ្ទះហ្នឹង បន្តិចចុងកៅគេយកនេះប៉ុឲ្យស្លរត្រឡោកដូងអត់មានកោសទេ ។

ដារ៉ា ៖ អាត្រឡោកដូងយើងហ្នឹង?

ស្រ៊ុន ៖ បាទ! នេះទុកដួសបាយ... មិត្តខ្ញុំ មិត្តហំ គាត់អត់ដួសទេ តែខ្ញុំចង់ដឹង បាយវាម៉េច បបរ៣ស្លាបព្រាគេ ខ្ញុំមកវិញ ។

ដារ៉ា ៖ អាស្លាបព្រា?

ស្រ៊ុន ៖ អាស្លាបព្រាយើងធម្មតា ចុះ៣០នាក់ អង្ករគេ៣កំប៉ុង មានអីប៉ុន្មាន ។

ដារ៉ា ៖ ហ្នឹងសំរាប់មួយពេល ឬក៏មួយថ្ងៃ?

ស្រ៊ុន ៖ មួយពេលអូន ។

ដារ៉ា ៖ ហើយមួយថ្ងៃគេឲ្យប៉ុន្មានពេលទៅ?

ស្រ៊ុន ៖ ២ពេល ។

ដារ៉ា ៖ តែ២ពេលទេ ខ្មែរក្រហម?

ស្រ៊ុន ៖ បាទ! មួយសន្ទុះខ្ញុំអត់ទាន់ហូបទេ រួចហើយបានគេថា ហ៎! ដួសសម្ល ខ្ញុំចង់ដឹងសម្លគេទៅទៀត កាន់ត្រឡោកហ្នឹងទៅទៀត ដល់គេស្ងរអាត្រកៀតយើង គេហាន់កង់ៗ ។

ដារ៉ា ៖ អីគេ?

ស្រ៊ុន ៖ ត្រកៀតយើង ដៃត្រកៀតយើង មិនមែនត្រកៀតសៗទេ ទងត្រកៀត អាត្រកៀតយើងធ្វើអង្រឹងហ្នឹង គេហាន់កង់ៗ ស្ងោរ ដល់ស្ងោរ ។

ដារ៉ា ៖ អាហ្នឹងកំប្លោកទេអី?

ស្រ៊ុន ៖ បាទ?

ដារ៉ា ៖ កំប្លោកទេអីគេធ្វើអង្រឹងហ្នឹង អីត្រកៀត?

ស្រ៊ុន ៖ ត្រកៀត ។

ដារ៉ា ៖ ត្រកៀត អាហ្នឹងគេហូបដែរ?

ស្រ៊ុន ៖ ពួកអ្នកទោសហើយស្រេចតែគេឲ្យអាអូន ខ្ញុំទៅៗគេដួសបានមួយវែកដែរ ខ្ញុំដាក់អីចឹងហើយខ្ញុំអង្គុយមើលគេ អាជាប់គុកមុនខ្ញុំគេស៊ីដូចឆ្ងាញ់ណាស់ ហើយខ្ញុំទើបតែចូលទៅជាប់អីចឹងវានៅជាតិបាយនឹងផ្ទះខ្លះ ខ្ញុំអត់ហូបទេ ខ្ញុំក្រឡេកមើលអ្នកណាស្គម ខ្ញុំឲ្យបាយហ្នឹងទៅ អ្នកណាស្គមជាងខ្ញុំ ខ្ញុំឲ្យសម្លហ្នឹងខ្ញុំអត់ហូបទេ ។

ដារ៉ា ៖ កាលហ្នឹងក្នុង៧៥ដដែរទេអ៎ី?

ស្រ៊ុន ៖ បែបក្នុង៧ហ្នឹងហើយ ៧៥ហើយអូន ដល់ហើយម្នាក់នោះប៉ុន្តែអ្នកជាប់ក្នុងហ្នឹងខ្លះទៅពីមន្ទីរទៅពីផ្ទឹកជ្រុំទៅអង្គរការដែរ ស្គាល់ខ្ញុំដែរ អ៊ំអើយហូបទៅ តែមានរូបមានទុក្ខហើយ ហើយនៅកន្លែងហ្នឹងបងឯងចាំមើលតែបន្តិចទៀត សត្វអីក៏ដោយឲ្យតែខ្លួនឡើងលើ ចំណីយើងទាំងអស់ ប្រាប់ខ្ញុំអីចឹង ចឹងចក់អីវិញមកអត់ទាន់ទេ វ៉ៃដុតៗស៊ី តែខ្ញុំអត់ហូបទេ រួចដល់ល្ងាចឡើងរបប គេនិយាយឲ្យអស់អូន កិនស្រូវ៨នាក់ ដៃត្បាល់កិនវេអីចឹង ម្នាក់៤នាក់អីចឹង ៤នាក់ម្ខាង ចុះអត់កំលាំង ដល់ដាក់ច្រើនទៅបានមានកំលាំង ចុះស៊ីអត់ឆ្អែតមិនអីចឹងកិនម្តង៤កញ្ជើរ ហើយនារីៗក៏មានជាប់គុកហ្នឹងដែរ រួចដល់នេះគេរោយអីចឹង គេអុំយកអង្កាមចេញយកទៅជាន់ ជាន់អង្ករ ត្បាល់កិនអីចឹង ជាន់ៗដល់ម៉ត់ ជាន់ដល់ភឹបហ្នឹងអង្ករជាមួយកំពែងត្បាល់ ជាន់ឲ្យម៉ត់ចង់បានកន្ទក់ទេ ដើម្បីកើបអង្ករអីចឹង បោសៗយើងយកអង្ករដាក់ក្នុងរោងបាយទៅ អត់ទាន់អុំទេ ហើយកន្ទក់យើងវេចយកទៅកន្លែងគុកយើង កន្លែងយើងដេកហ្នឹង ដេកទៅវាទន្ទឹមគ្នាអាហ្នឹង ក្បួនដេកប៉ុន្តែខ្ញុំទៅមិនទាន់ គ្រាន់តែឃើញ អាដែកកងវានេះ ដាក់អីចឹងចូលក្នុងកង រនុកឈើ តែខ្ញុំទៅ ខ្ញុំអត់ទាន់ដាក់ទេ ខ្ញុំគ្រាន់តែឃើញហើយបានកេះគ្នាៗឲ្យ ដូចថាឲ្យមួយស្វាបព្រាអីចឹង កន្ទក់ហ្នឹង ហើយឲ្យខ្ញុំដាក់ដៃអីចេះ

ដល់ហើយខ្ញុំលិតទឹកមាត់អីចឹង ដាក់អីចឹងស្រួបអីចឹង អត់ផ្អែមអីណា ហើយខ្ញុំដោយសារតែសុខភាពខ្ញុំ ខ្ញុំអត់ហ៊ានហូបទេ ខ្ញុំខ្លាចវាទល់វាអី ខ្ញុំកេះអាក្បែរហ្នឹង ឲ្យអាហ្នឹងទៀតទៅ អូនឯងមើលខ្ញុំ វេទនាណាស់អូនទៅហ្នឹង។

ដារ៉ា : ពេល១-២ថ្ងៃមុនដំបូង អ៊ំទៅអត់មានបានពិសារអីទេ?

ស្រ៊ុន : អត់។

ដារ៉ា : នៅកន្លែងមន្ទីរហ្នឹង វាជាមន្ទីរ ឬជាគុកអ៊ំ?

ស្រ៊ុន : ខ្ញុំទៅមិនទាន់ទេ ប៉ុន្តែមន្ទីរដែរ តែមន្ទីរណាស់ មន្ទីរដែរ។

ដារ៉ា : មន្ទីរធ្វើការងារគេ ឬមន្ទីរសន្តិសុខ?

ស្រ៊ុន : មន្ទីរសន្តិសុខ។

ដារ៉ា : មន្ទីរសន្តិសុខម៉ង?

ស្រ៊ុន : សំរាប់ទទួលពីនេះទៅ ដូចថាឈ្លើយសឹក ខ្ញុំវិញសុទ្ធតែឈ្លើយសឹក។

ដារ៉ា : មន្ទីរសន្តិសុខហ្នឹង មន្ទីរសន្តិសុខ២០៨?

ស្រ៊ុន : បាទៗ។

ដារ៉ា : អ្នកណាជាអ្នកគ្រប់គ្រងមន្ទីរហ្នឹង?

ស្រ៊ុន : គ្រប់គ្រងមន្ទីរហ្នឹង តាឆេន មិនដឹងស្អី ឆេន។

ដារ៉ា : ឈ្មោះ តាឆេន?

ស្រ៊ុន : បាទ!

ដារ៉ា : តាឆេន អ្នកនៅស្រុកភូមិជាមួយអ៊ំ?

ស្រ៊ុន : បែបមិនមែននៅហ្នឹងទេអូន បែបខ្ញុំស៊ើបសួរបែបនៅកំពង់ចាម។

ដារ៉ា : មកពីកំពង់ចាមវិញ តាឆេន ហ្នឹង?

ស្រ៊ុន : បាទ!

ដារ៉ា : ហើយពេលអ៊ំចូលទៅដល់ដំបូង នៅក្នុងរោងហ្នឹងអ៊ំថាឃើញមាន អ្នកទោសនៅហ្នឹងស្រាប់ហើយ?

ស្រ៊ុន : នៅ៣០នាក់។

ដារ៉ា : ៣០នាក់ជាង?

ស្រ៊ុន : បាទ!

ដារ៉ា: មានស្រី មានប្រុសអីចឹងទៅ?

ស្រ៊ុន: មានស្រី មានប្រុស។

ដារ៉ា ៈ មានក្មេងដែលអី?

ស្រ៊ុន ៈ ក្មេងមានដែរ ក្មេងតូច ក្មេងខ្លះពោះធំទៀត មិនមែនពោះធំពីនេះទៅទេអូន គេចាប់យកទៅ វាទៅកើតនៅហ្នឹង ដល់វាឃ្លានពេក អត់មានជាតិដោអីកើតបានមួយយប់ហ្នឹងឆ្លងពីមន្ទីរ ២០៤ មកព្រែកក្បៀន ដើម្បីសុំបាយ សុំទឹកគេស៊ី មកលើកទី១រួចខ្លួន ដល់លើកទី២គេ យកទៅវៃចោលនៅភ្នំដាច់អូន យកទៅវៃចោលនៅភ្នំដាច់ចោលកូននោមន្ទីរហ្នឹង។

ដារ៉ា ៈ ពេលដែលក្មេងជាប់នៅមន្ទីរឃុំឃាំង ដែលមានស្រី មានប្រុស ការជាប់គេមានបែងចែកឲ្យ នៅប្រុសផ្សេង ស្រីផ្សេង ឬយ៉ាងណា?

ស្រ៊ុន ៈ ប្រុសផ្សេង ស្រីផ្សេង។

ដារ៉ា ៈ អត់មែននៅច្របូកច្របល់គ្នាទេ?

ស្រ៊ុន ៈ អត់ទេ។

ដារ៉ា ៈ នៅក្នុងខ្ទមតែមួយ ឬខ្ទមដាច់ដោយឡែក?

ស្រ៊ុន ៈ ខ្ទមតែមួយ។

ដារ៉ា ៈ ខ្ទមតែមួយ គ្រាន់តែដាក់ដោយឡែកជួរគ្នាអីចឹង?

ស្រ៊ុន ៈ ជួរគ្នាតែដាច់ដោយឡែកអីចឹង ខាងស្រីផ្សេង ខាងប្រុសផ្សេង។

ដារ៉ា ៈ តែជ្រកនៅក្នុងខ្ទម រោងតែមួយ?

ស្រ៊ុន ៈ បាទ! ប៉ុន្តែយប់ឡើងគេអនុញ្ញាតឲ្យដុតភ្លើងពីក្រោមដែរ ការពារកុំឲ្យខ្លាមកពាំ អូននៅ កណ្តាលព្រៃតែម្តង អាចថាគុកអត់ជញ្ជាំងប្រាកដមែន ដើរអត់កើត អត់ហ៊ានទេ។

ដារ៉ា ៈ មន្ទីរហ្នឹងនៅក្នុងទឹកដីឃុំអី ស្រុកអី ភូមិអី?

ស្រ៊ុន ៈ បេះអូនមន្ទីរហ្នឹងកាល តាម៉ុក គាត់យកទៅដាក់នៅកន្លែងហ្នឹង ថាខេត្តតាកែវ ដល់បែងចែក ទៅកំពង់ស្ពឺវិញនេះ ខាងកំពង់ស្ពឺគេយកដីហ្នឹងវិញ ដីអាដែងអូកមន្ទីរហ្នឹង ដល់ខាងកំពង់ស្ពឺគេ យកដី តាម៉ុក យកប្រជាជនមកវិញព្រោះប្រជាជនយើង យកមកវិញមក កាលហ្នឹងក៏ គេដើរវើខ្លាំងណាស់ដែរ ខ្ញុំអត់ទាន់បានចេញពីមន្ទីរហ្នឹងទេ ដល់យូរប្រហែល២ឆ្នាំ បានមាន សិទ្ធមកនៅព្រៃក្តួច ភូមិព្រៃក្តួច។

ដារ៉ា ៈ អីចឹងអ៊ំនៅមន្ទីរហ្នឹងប្រហែលជារយៈពេល២ឆ្នាំ?

ស្រ៊ុន ៈ បាទ!

ដារ៉ា ៈ ចុះឆ្នាំណាដែលមន្ទីរហ្នឹងត្រូវបានកាត់ឲ្យទៅខាងកំពង់ស្ពឺ? អ៊ំនៅបានប៉ុន្មានឆ្នាំបានគេកាត់ អាហ្នឹង?

ស្រ៊ុន ៈ ទៅបោយប៉ែត២ឆ្នាំអូន។

ដារ៉ា ៈ ទៅ២ឆ្នាំ?

ស្រ៊ុន ៈ ភ្លេចឆ្នាំទៀតខ្ញុំ ។

ដារ៉ា ៈ អីចឹងអ៊ំរស់នៅហ្នឹងរយៈពេល២ឆ្នាំ?

ស្រ៊ុន ៈ បាទ!

ដារ៉ា ៈ ជាអ្នកទោសហ្នឹង?

ស្រ៊ុន ៈ អ្នកទោសហ្នឹងអូន ។

ដារ៉ា ៈ ហើយឲ្យធ្វើការងារអីខ្លះអ៊ំ?

ស្រ៊ុន ៈ ខ្ញុំគេឲ្យរែកទឹក ដំបូងរែកទឹកជ្រោះឡើងភ្នំនេះ ។

ដារ៉ា ៈ រែកទឹកណា?

ស្រ៊ុន ៈ រែកចាក់ពាងឲ្យគេប្រើការ អត់មានអណ្តូងទេ ប្រហែលជា៣០អំរែកទេមួយថ្ងៃ ។

ដារ៉ា ៈ ១ថ្ងៃ៣០អំរែក?

ស្រ៊ុន ៈ បាទ! រួចដល់ហើយពេលដែលគេធ្វើស្រែក្បែរទំនប់ហ្នឹង គេភ្ជួរ គេភ្ជួរហ្នឹង ភ្ជួរទាំងមនុស្ស ដែរ ។

ដារ៉ា ៈ អីចឹងទៀត?

ស្រ៊ុន ៈ បាទ! ទឹមមនុស្ស ទឹមមួយអីចឹង២នាក់ៗ អ្នកភ្ជួរនៅក្រោយ អ្នកនោះអូស អូសៗទៅ អាភ្ជួរអូសល្មមទេ ធំបំផុតអាអូសរនាស់ ។

ដារ៉ា ៈ អូសរនាស់?

ស្រ៊ុន ៈ បាទ! ខ្ញុំដួល២សារ ដួល២-៣សារខ្ញុំ ។

ដារ៉ា ៈ អីចឹងអ្នកដែលគេទឹមដូចជាគោ ដូចក្របីហ្នឹង ជាអ្នកទោស ឬប្រជាជនធម្មតា?

ស្រ៊ុន ៈ អ្នកទោសដូចខ្ញុំវិញ ចេញពីភ្នំពេញគេរាយការណ៍ថាសក្តិពាកខ្លះ បានចូលទៅដល់ហ្នឹង គេថា ពួកសក្តិភូមិអូនឯង បាទអាហ្នឹងអីចឹង មិនមែនទោសលួចប្លន់អីណាអត់ទេអូន ។

ដារ៉ា ៈ អ្នកដែលនៅជាប់ឃុំនៅមន្ទីរហ្នឹងអ៊ំ?

ស្រ៊ុន ៈ បាទ!

ដារ៉ា ៈ តែអ៊ំគ្រាន់តែគេឲ្យរែកទឹក?

ស្រ៊ុន ៈ រែកទឹក ហើយនិងអូសរនាស់ដែរ អូសរនាស់បាន២ព្រឹកដែរ តែខ្ញុំដួលពេក ចុះគេឡើងជិះ ហើយជីជុង ។

ដារ៉ា ៈ ហើយអ្នកណាជាអ្នកវាស់ អ្នកភ្ជួរ ជាអ្នកជាប់នៅក្នុងមន្ទីរហ្នឹងដែរ ឬ?

ស្រ៊ុន ៈ អ្នកជាប់នៅមន្ទីរហ្នឹងដែរ តែធ្វើតាមបញ្ជីរបស់អ្នកគ្រប់គ្រងមន្ទីរហ្នឹង ។

ដារ៉ា ៖ អីចឹងរយៈពេលដែលអ៊ំនៅ២ឆ្នាំ នៅមន្ទីរ២០៨ហ្នឹង គឺប្រធានមន្ទីរ តាឆេន រហូតមានផ្លាស់ប្តូរទេ?

ស្រ៊ុន ៖ អត់ទេអូន។

ដារ៉ា ៖ ហើយមានស្គាល់អ្នកណាទៀត ជាសន្តិសុខ ជាអីខ្លះ? មានស្គាល់ឈ្មោះទេ?

ស្រ៊ុន ៖ សន្តិសុខខ្ញុំមានស្គាល់ ស្គាល់ដែរតែទៅពីក្រៅ។

ដារ៉ា ៖ ទៅក្រៅ?

ស្រ៊ុន ៖ បាទ! ក្រៅ។

ដារ៉ា ៖ អីចឹងការងារមួយរយៈពេល២ឆ្នាំហ្នឹង អ៊ំ?

ស្រ៊ុន ៖ វេទនាណាស់អូន គេឲ្យកាស់ព្រិចទៀតខ្ញុំ កាស់គល់ព្រិចដើម្បីដាំដំឡូង យកព្រិច ដល់ហើយវាឈឺធ្មេញៗ ទៅប្រាប់នេះ ខ្ញុំភ្លេចហើយនៅត្រពាំងគល់យើងនេះដែរ ខ្ញុំថា ខ្ញុំឈឺធ្មេញមានថ្នាំដែលអត់ អីចឹង មានថ្នាំអត់ ប៊ុស៊ីម នៅត្រពាំងគល់មួយទៀតអូន ប៊ុស៊ីម អនុប្រធានពូឆេន ហ្នឹង។

ដារ៉ា ៖ ឈ្មោះអីគេ?

ស្រ៊ុន ៖ អនុប្រធាន ឈ្មោះ ស៊ីម នៅខាងលិចត្រពាំងគល់ ខ្ញុំឈឺធ្មេញទៅសុំថ្នាំគេ អត់មានគេឲ្យខ្ញុំខំគល់ព្រិច ខំឲ្យខ្លាំងទៅចេញខ្ទុះលែងឈឺហើយ អូនឯងមើលធ្វើអីចឹងៗទៀត គល់ព្រិចថ្នាំងវាខ្លីៗ(យំ)។

ដារ៉ា ៖ អ៊ំនៅហ្នឹងដល់រយៈពេល២ឆ្នាំ ចុះប្អូនអ៊ំ, អ៊ំពត ពេលណាដែលគាត់ដឹងថាអ៊ំមកជាប់គុកនៅហ្នឹង?

ស្រ៊ុន ៖ ពេលដែលជាប់គុកហ្នឹងអីចេះ អីចឹងបានថាបើពិភាក្សាប្អូនខ្ញុំវាត្រូវម្យ៉ាងដែរ ពេលដែលជាប់គុកញ៉ឹក ក្នុងមួយឆ្នាំម៉ែខ្ញុំយំនៅរបងគុកនេះ ២ដង (យំ) ទប់ចិត្តថ្លើមពេកទៅ បើចាប់វាដាក់គុកក៏វាដឹងដែរ ថាបងវានៅសាលាខេត្តអីចឹង ........ដល់គេចាប់ដាក់គុកខ្ញុំទិសដៅរបស់ខ្ញុំគេត្រូវកំទេច។

ដារ៉ា ៖ អ៊ូ! ត្រូវកំទេចអីចឹង?

ស្រ៊ុន ៖ ត្រូវកំទេច ប៉ុន្តែគេខ្លាចប្អូនខ្ញុំធ្វើការបដិវត្តន៍ដែរហ្នឹង គេទុកទៅ ទុកឲ្យយើងស្លាប់តាមយថាហេតុទៅ ដល់យើងអត់ស្លាប់ចេះតែរស់នៅ។

ដារ៉ា ៖ គេអត់ហ៊ានយកទៅកំទេចទេ?

ស្រ៊ុន ៖ បាទ!

ដារ៉ា ៖ គេឲ្យរស់នៅតាមយថាកម្មទៅ ស្លាប់ថ្ងៃណា អីថ្ងៃណា?

ស្រ៊ុន ៖ បាទ!អីចឹង ....អ្នកណាម្នាក់ ដល់ខ្ញុំមកនេះ វាថាយកព្រំដែនទៅដឹងទេ បញ្ជូនមកហ្នឹងគេសួរសារបានអ្នកណានៅណាអីណា កូនចៅបងប្អូនវាប៉ះដល់ខ្ញុំធ្វើការនៅសាលាខេត្តដែរ ខ្ញុំនៅដែនការខេត្ត ខ្ញុំនៅតាកែវ បានម៉ែខ្ញុំគាត់លែងទឹកភ្នែក ...អូន ។

ដារ៉ា ៖ មន្ទីរ២០៤ មានយូរមកហើយ ឬម៉េចអ៊ំ?

ស្រ៊ុន ៖ ខ្ញុំអត់ដឹង ពេលដែលចូលទៅគ្រាន់តែពួកចាស់ៗចេញពីអន្តរលាយទៅ នៅខាងត្បូងផ្លូវកជ្រៃ ថាមន្ទីរហ្នឹង ទេមិនមែនដាក់មន្ទីរទេ នេះព្រៃក្តួចៗមន្ទីរហ្នឹងនៅខាងលិចព្រៃក្តួចបេះ នេះព្រៃក្តួចនៅខាងលិចភូមិព្រៃក្តួចហ្នឹងវាមិនមន្ទីរ២០៤ សំរាប់ដាក់មនុស្សដែលខុសនៅក្នុងភូមិយកទៅដាក់ហ្នឹង ហើយអ្នកដែលគាត់ទៅៗ១វង់នៅកន្លែងនេះ គាត់ថាដាក់រទេះទៅប៉ុន្មានមិនដឹង ៣០-៤០រទេះយកទៅដាក់កណ្តាលគល់ព្រិចម៉ង រួចគោយំមិនដឹងរកទឹកដឹកឯណាអាអូរស្ការនេះធ្វើរោងបោះតង់បោះអីនៅនេះ ទៅបីពាន់នៅសល់មួយរយម្ភៃ ទៅបីពាន់នាក់ដឹកយកទៅចាក់ដំបូង នៅសល់មួយរយម្ភៃអូន យ៉ាប់បីពាន់នៅសល់មួយរយម្ភៃ ហើយអាកន្លែង នេះចាញ់ហើយ ចាញ់អាមន្ទីរ២០៤ ចាញ់ហើយ ម្នាក់នោះប្រាប់ខ្ញុំថាកន្លែងហ្នឹងគេហៅថា ព្រៃក្តួចទៅមន្ទីរក្តួចចំណីខ្មោចទាំងអស់អូន ។

ដារ៉ា ៖ មន្ទីរហ្នឹងនៅជិតវត្តអ៊ំអី? ជិតវត្តព្រៃក្តួចអី?

ស្រ៊ុន ៖ កាលហ្នឹងអត់ទាន់មានវត្តទេ អត់ទាន់មានវត្ត មានតែវត្តដុងនៅជើង វត្តដុង ។

ដារ៉ា ៖ តែអាហ្នឹងគេហៅភូមិព្រៃក្តួចអីម៉េច?

ស្រ៊ុន ៖ បាទ! ភូមិព្រៃក្តួច ។

ដានី ៖ ក្នុងឃុំដុងអាហ្នឹង?

ស្រ៊ុន ៖ កាលមុនឃុំដុង កាលនៅព្រៃក្តួច ។ អេ៎! ឈប់កុំអាលដាក់អូន ដូចជាឃុំអូរសារ៉ាយទេអូនបាទ! ឃុំអូរសារ៉ាយទេ ឃុំអូរសារ៉ាយកាលជំនាន់ប៉ុលពត ។

ដារ៉ា ៖ នៅក្នុងស្រុកត្រាំកក់ហ្នឹងដែរ?

ស្រ៊ុន ៖ អូរសារ៉ាយ ស្រុកត្រាំកក់ ទៅពីនេះទៅមានទំនប់អីមួយ ហៅទំនប់ធំអូន ។

ដារ៉ា ៖ ហើយមន្ទីរហ្នឹងនៅខាងកើត, ខាងលិច, ខាងជើង អីដែរនៅភូមិព្រៃក្តួច?

ស្រ៊ុន ៖ នៅខាងលិចភូមិព្រៃក្តួច ។

ដារ៉ា ៖ ខាងលិច?

ស្រ៊ុន ៖ បាទ! មនុស្សជំនាន់ហ្នឹងអូនឯងដូចថា វ៉ៃប្រពន្ធមួយដែលឆ្លងទន្លេហើយ៣ថ្ងៃមកភូមិព្រៃក្តួចហ្នឹង ដល់វានៅចាំៗ ហើយដល់ហើយវាចាប់យកទៅកំទេចក្បែរភ្នំដាច់ អាភ្នំដាច់ហ្នឹងគ្រាន់តែមនុស្សរកប់៣០នាក់ រួចអាប្តីមួយអាមួយស្គមដាងគេបង្អស់ធ្វើអីអត់កើត គេឲ្យមើលគោអូន

មើលគោ មើលក្របី ដល់ហើយអាគោ៣០គ្រឿងហ្នឹងវាទៅដល់ វាស៊ីតែឆ្អឹងខ្មោចក្បែរភ្នំហ្នឹងទេ ។

ដារ៉ា ៖ ភ្នំអីគេម៉ិញ?

ស្រ៊ុន ៖ ភ្នំដាច់ ។

ដារ៉ា ៖ ភ្នំដាច់?

ស្រ៊ុន ៖ បាទ! ទៅស៊ីតែឆ្អឹងខ្មោចនៅហ្នឹង ដល់វាទៅដេញគោ ដល់ដេញគោវាឃើញអាដែងដូចជាក្រមាប្រពន្ធវាមិនដឹង វាមកប្រាប់អាអ្នកនៅក្បែរហ្នឹងថា ប្រពន្ធខ្ញុំគេយកទៅកប់ខាងជើងភ្នំខ្ញុំឃើញក្រមា ល្ងាចហ្នឹងចងលួនទៅគាស់យកថ្ងៃមមកហូបអីចឹងទៀត ។

ដារ៉ា ៖ បបួលអីចឹងទៀត?

ស្រ៊ុន ៖ បាទ! ប្រពន្ធវា ។

ដារ៉ា ៖ ដល់ឃ្លានខ្លាំងពេកអី?

ស្រ៊ុន ៖ អូនឯងមើល អ្នកជិតខាងថាអត់ទៅទេ អត់ទៅ អាមើលគោហ្នឹងអូនឯងមើលគ្រាន់តែត្រូវដំបង៣-៤សារ ដល់មើលគោទៅវាដូចជាយាប់ពេក គេឲ្យមើលក្របី កាលណាដេញក្របីទៅជិះលើខ្នងក្របីអូនណា៎ យកទៅឲ្យចុះទឹកអូរ ទឹកអីចឹង វាស៊ីអីចឹង អាក្របីហ្នឹងឈ្លើងវាទាមពោះ ឈ្លើងទាមពោះក្របី វាចាប់ឈ្លើងហ្នឹងដុតអូន ដុតស៊ី កាលណាដុតទៅវាមិនឆាប់វាប៉ោងៗវាឈាមនៅក្នុងហ្នឹង ខាំជ្រិចទៅវាខ្ទាត់ប្រឡាក់ឈាម ប្រឡាក់អី គេទៅតាមវៃគ្នានៅក្បែរហ្នឹងទៀត វៃទៀតអូន បានអាណោចអាធមណាស់ជីវិតមុននឹង ។

ដារ៉ា ៖ សន្តិសុខ ឬកម្មាភិបាល ឬជាសន្តិសុខច្រើននាក់ទេ នៅក្នុងមន្ទីរហ្នឹង?

ស្រ៊ុន ៖ សន្តិសុខ សន្តិសុខ ហ៎! ជាងដប់នាក់ ។

ដារ៉ា ៖ ជាងដប់នាក់ទេ?

ស្រ៊ុន ៖ បាទ!

ដារ៉ា ៖ មានកាំភ្លើងមានអីទេ?

ស្រ៊ុន ៖ មាន! អូន ។

ដារ៉ា ៖ ចុះក្នុងរយៈកាលអីរស់នៅក្នុងកន្លែងមន្ទីរហ្នឹង ដែលលឺស្នូរកាំភ្លើងដែរ? អាចថាជាស្នូរកាំភ្លើងបាញ់សម្លាប់អ្នកទោស អ្នកអី?

ស្រ៊ុន ៖ មិន ខ្ញុំលឺជាចេះប៉ុន្តែខ្ញុំមិនដែលទៅដល់ហ្នឹងទេ នៅជុំវិញមន្ទីរម្តុំអស់នេះវិញ គេដាំពោត ប៉ុន្តែកាប់ជ្រុងខ្ញុំអត់ដែលទៅទេ អ្នកខ្លះប្រាប់ខ្ញុំថាអាហ្នឹងហើយអណ្តូងជ្រៅណាស់អានេះ អណ្តូងវៃខ្មោច វៃអ្នកទោសនៅក្នុងហ្នឹង បានថាឲ្យវៃ វៃក្នុងហ្នឹង អត់ហ៊ានបាញ់ទេ វៃសម្លាប់ហ្នឹងតែ

ម្តង អ្នកខ្លះអត់ទេ វ៉ៃតែមួយភឺបចូលក្នុងអណ្តូងឈ្លក់ទឹកខ្មោចក្រោមហ្នឹងក៏ងាប់ដែរ មិនបាច់ឲ្យងាប់ពីលើទៅទេ ។

ដារ៉ា : ហ្នឹងនៅខាងណាមន្ទីរ?

ស្រ៊ុន : ខាងជ្រុងបេះមន្ទីរៗ តែខ្ញុំអត់ដែលទៅមើលទេគេថា ។

ដារ៉ា : យើងដឹងថាខាងជើង ខាងត្បូង?

ស្រ៊ុន : ខាងត្បូង ត្បូងឈានខាងលិចអូនណា៎ តែអ្នកប្រាប់ខ្ញុំមិនដឹងអ្នកណាភ្លេចហើយ មិនដឹងអ្នកណា ខ្ញុំអត់ដែលទៅលឺគេថាអីចឹងខ្ញុំអ្នកខ្លាច ប្រហែលជាការពិតបាននិយាយអីចឹងអូនណា៎ បាននិយាយប្រាប់អីចឹង ថាទៅអន្ទុយមាត់រណ្តៅដាក់ជួស ដួកៗទៅវាឈ្លក់ទឹកខ្មោចខាងក្រោមមិនបាច់វ៉ៃឲ្យងាប់ពីលើទៅទេ និយាយប្រាប់ថាអីចឹង អាណោចអាធមណាស់មិនសមអីចឹងសោះខ្មែរ ។

ដារ៉ា : អីចឹងអ៊ំជាប់នៅមន្ទីរហ្នឹងដល់ឆ្នាំ? រយៈពេល២ឆ្នាំអីចឹងអ៊ំ?

ស្រ៊ុន : បាទ! រយៈពេល២ឆ្នាំ ។

ដារ៉ា : អីចឹងវាអាចចូលដល់ឆ្នាំ៧៧នោះ ។

ស្រ៊ុន : អាចហើយ ព្រោះ៧៩ ថ្ងៃ២៥ ខែ៧ ៧៩ ខ្ញុំចូលពាណិជ្ជកម្ម ខ្ញុំទៅហ្នឹងទៀត ទៅទៀតគេហៅ ដូចថាគេឃោសនា ។

ដារ៉ា : អ៊ំមានប្រសាសន៍ថាមានការកាត់ឲ្យ កន្លែងដីធ្មើមន្ទីរហ្នឹងទៅខាងកំពង់ស្ពឺ?

ស្រ៊ុន : ហ្នឹង តាម៉ុក អីយកប្រជាជនមកវិញខាងតាកែវ អ្នកឯងយកដី ខ្ញុំយកប្រជាជនមកវិញ ដល់មកដល់នៅកន្លែងហ្នឹងទៅ គេចាប់ប្អូនខ្ញុំទាំងអស់ហ្នឹងឲ្យទៅនៅបន្ទាយដែក គគីរកៀនស្វាយអូន ខ្ញុំនឹកឃើញថា ខ្ញុំទៅដែរ បើគេឃាត់អាហ្នឹងចាំនៅ បើគេទៅខ្ញុំទៅដែរនឹកឃើញថានៅក្បែរ នៅជិតម៉ែជិតឪ គេយកមិនប្រាប់ម៉ែឪខ្ញុំផងយកខ្ញុំ ចុះទំរាំម៉ែឪខ្ញុំទៅនោះខ្ញុំនៅនេះដូចវាលពេកខ្ញុំរត់តាមៗ អត់មានអ្នកណាថាអីទេ ខ្ញុំទៅនៅឃុំបន្ទាយដែក ។

ដានី : ទៅជាមួយពីណាគេហ្នឹង?

ស្រ៊ុន : នៅជាមួយ តាមុញៗ មិនមែនទេគេជម្លៀសទៅប្រជាជនទាំងអស់ហ្នឹង ទៅនៅភូមិអស់ហ្នឹងដែរ ហើយខ្ញុំទៅនៅហ្នឹងដែរ បងស្រីខ្ញុំក៏នៅហ្នឹងដែរ បងស្រីអូនណា៎នៅហ្នឹង នៅហ្នឹងដែរ ខ្ញុំនៅផ្ទះដោយខ្លួនទេ ប៉ុន្តែមនុស្សដូចគ្នាទៅនៅហ្នឹងដែរ ។

ដារ៉ា : អ៊ំពត ថាគាត់ទៅកៀនស្វាយ គាត់ទៅឃុំកំពង់ស្វាយតាំងពី៧៥ណោះអ៊ំ ។

ស្រ៊ុន : ប្រហែលហើយ ។

ដារ៉ា ៖ ពេលដែលបែកខ្មែរក្រហមបានកាន់អំណាចភ្លាមៗហ្នឹង អីចឹងបើសិនជាអ៊ំថាទៅជនាន់ អ៊ំពត ទៅកៀនស្វាយដែរ អីចឹងមានអ៊ំអត់បានជាប់នៅមន្ទីរឃុំឃាំងៗ

ស្រ៊ុន ៖ ខ្ញុំជាប់ប្រាកដណាស់ខ្ញុំ ៗ

ដារ៉ា ៖ អត់ទេ ចង់និយាយរយៈពេលអ៊ំ ខ្ញុំចង់សួរបញ្ជាក់រយៈពេល ព្រោះអ៊ំថាជាប់នៅមន្ទីរ២០៤ រហូតដល់ទៅ២ឆ្នាំ បើ២ឆ្នាំអាចថាដល់ឆ្នាំ៧៧ តែអ៊ំពត គាត់ទៅកៀនស្វាយហ្នឹងឆ្នាំ៧៥ ៗ

ស្រ៊ុន ៖ ៧៥?

ដារ៉ា ៖ បាទ! ឆ្នាំ៧៥ អីចឹងអ៊ំជាប់នៅមន្ទីរហ្នឹងរយៈពេលប៉ុន្មានអីពិតប្រាកដអ៊ំ អ៊ំរកនឹកឃើញ នឹកឡើងវិញ?

ស្រ៊ុន ៖ ពិតប្រាកដប្រហែលជា បើមិនពីរ ក៏លើសពីមួយដែរអូនដែរ លើសពីមួយដែរៗ ចេញពីមន្ទីរមកនៅព្រៃក្ដួចហ្នឹង មានសិទ្ធនៅព្រៃក្ដួច ដល់ស្គមពេកអីចឹងទៅ ដំរាបឲ្យត្រង់ទៅ មកដល់គេអត់ឲ្យប្រើអី គេប្រើឲ្យកាត់ស្មៅគោ គោឈឺៗកាត់ស្មៅ និយាយពីអាណោចអាធមណាស់បើអូន បើបានផាប់មែនបានតែហូបសាច់គោហ្នឹងបានមានកំលាំង មានអីបានតែ៣, ៤-៥ថ្ងៃផាប់មែន គោហ្នឹងៗ

ដារ៉ា ៖ ហើយបានហូបគោហ្នឹងដែរ?

ស្រ៊ុន ៖ បានហូប គេឲ្យក្បាលមាត់ ហើយនិងជើងដៃ ដឹងលុះឥលូវថាអាគោឆ្ងាញ់ជើងដៃ ហើយនិងក្បាល ហើយកាលជំនាន់ហ្នឹងអុសវានៅសំបូរ និយាយពីស្ងោរហូប អន្ទុយហូបដូចក្របីដាច់យប់អីចឹង អត់មានអំបិលអីហូបទេៗ

ដារ៉ា ៖ ឆ្ងាញ់ណាស់?

ស្រ៊ុន ៖ ឆ្ងាញ់ចេះតែឆ្ងាញ់ហើយ បន្ទាប់មកទៀតក្របីមួយទៀតឈឺទៀត ឈឺផាប់ទៀត ហូបទៀត បានក្របីហ្នឹងៗ

ដារ៉ា ៖ អីចឹងបន្ទាប់ពីអ៊ំត្រូវបានគេឲ្យទៅនៅក្ដួចហ្នឹងហើយ?

ស្រ៊ុន ៖ បាទៗ ៗ

ដារ៉ា ៖ បាន

ស្រ៊ុន ៖ មានសិទ្ធៗ

ដារ៉ា ៖ មានសិទ្ធ

ស្រ៊ុន ៖ មានសិទ្ធហ្នឹងគឺថា មានផ្ទះនៅកន្លែងហ្នឹង មានមាន់ មានទាអីនៅកន្លែងហ្នឹង ពងអីនៅកន្លែងហ្នឹង គេថាអត់ទេឲ្យទៅប្រជុំនៅគោកកណ្ដាល គោកកណ្ដាលនៅខាងលិចវត្តផុង ខាងលិចបសេដ្ឋកាត់ផ្លុកស្រុករការធំហ្នឹង ខាងលិចភ្នំគោកភ្នំកក់ហ្នឹង ឲ្យទៅទាំងប្រពន្ធទាំងកូន ហើយ

គោចង់ទុកនៅខាងក្រោមផ្ទះ មាន់ ទា ក្រាបនៅនេះអត់ទេ ទៅប្រពន្ធកូន បានគេជម្លៀសមក តាមផ្លូវហ្នឹងមក មកកើតអត់មានយកអី បានថាអត់ ក្បួនវាធ្វើអីចឹងទៀតអូន មើលៗឲ្យទៅទាំងអស់ មានអ្នកណាបានយកអីទៀត គេដេញអស់ពីផ្ទះ ។

ដារ៉ា ៖ ទៅខ្លួនទទេ?

ស្រ៊ុន ៖ ខ្លួនទទេ ។

ដារ៉ា ៖ ហើយបានជម្លៀសទៅដល់ឃុំបន្ទាយដែក?

ស្រ៊ុន ៖ ឃុំផុង ឃុំផុងសិន បន្ទាយដែកបានគេជម្លៀសទៅៗ ដូចទៅនៅស្រុក ទៅនៅស្រុកបានប៉ុន្មានថ្ងៃបានគេរៀបចំបញ្ជូនអ្នកអស់ហ្នឹងឲ្យទៅនៅកៀនស្វាយ គេហៅថាកៀនស្វាយ ប៉ុន្តែឃុំបន្ទាយដែក ។

ដានី ៖ អ៊ំជម្លៀសទៅនៅកៀនស្វាយ ទៅនៅជាមួយ អ៊ំពត ដែរ?

ស្រ៊ុន ៖ អ៊ំពត អត់នៅហ្នឹង អ៊ំពត ដូចនៅកណ្តាលស្ទឹងវិញ ។

ដារ៉ា ៖ អ៊ំពត គាត់ទៅដំបូងគាត់នៅកំពង់ស្វាយ ដល់ក្រោយមកបានគាត់មកនៅឃុំបឹងខ្យាងកណ្តាលស្ទឹង ។

ស្រ៊ុន ៖ បឹងខ្យាង កណ្តាលស្ទឹង ។

ដានី ៖ អីចឹងអត់នៅជាមួយគ្នា ពេលជម្លៀសទៅកៀនស្វាយ ទៅបន្ទាយដែកហ្នឹង អត់នៅជាមួយគាត់ទេ?

ស្រ៊ុន ៖ អត់ជាមួយគ្នាទេ អត់ទេ ឡានផ្សេងគ្នា អត់ជាមួយគ្នាទេ តែខ្មែររយៈគេនៅកន្លែងហ្នឹងអីដូចថាគេស្គាល់គ្នាទៅពីនេះទៅអីចឹង ឧទាហរណ៍ថាមេឃុំនៅបន្ទាយដែកហ្នឹង ប៉ុអីមួយនៅព្រៃស្បាតអីចឹង ម្នាក់ហ្នឹងស្គាល់អីចឹង មកលិចៗអត់ស្គាល់ទេ សូម្បីតែខ្ញុំក៏អត់ស្គាល់មេឃុំបន្ទាយដែកហ្នឹងដែរ ប៉ុន្តែបងប្អូនម៉េចក៏ថាមានការអត់ធ្មត់អីចេះចុះ គ្រាន់តែថាឲ្យមើលអីចេះចុះផង ខុសត្រូវចេះចុះ មនោសញ្ចេតនាខ្មែរយើងមិនដាច់ទេមនោសញ្ចេតនា ។

ដារ៉ា ៖ កាលអ៊ំជាប់នៅមន្ទីរឃុំឃាំង មន្ទីរ២០៨ហ្នឹង ចុះគ្រួសារអ៊ំ កូនចៅអ៊ំអីម៉េច?

ស្រ៊ុន ៖ គ្រួសារខ្ញុំនៅអង្គរការ ។

ដារ៉ា ៖ នៅអង្គរការ?

ស្រ៊ុន ៖ បាទ! នៅអាផ្ទះប្រឡាយ ពីប្រឡាយទៅផ្ទះប្អូនខ្ញុំ កើតបន្តិចមក អាហ្នឹងភូមិដើមដូង ។

ដារ៉ា ៖ នៅហ្នឹង?

ស្រ៊ុន ៖ ដល់ខ្ញុំមានសិទ្ធចេញពីមន្ទីរមកនៅព្រៃក្តួច បានក្រុមគ្រួសារទៅនៅហ្នឹង នៅមូលគ្នា ។

ដារ៉ា ៖ អីចឹងគ្រួសារអ៊ំបានទៅនៅព្រៃក្តួចហ្នឹងដែរ?

ស្រ៊ុន ៖ បាទ! នៅព្រៃក្តួចដែរ ។

ដាវ៉ា ៖ បាននៅជុំគ្នាហ្នឹងហើយ បានមានការជម្លៀសទៅកៀនស្វាយ?

ស្រ៊ុន ៖ បាទ! ទៅផុតៗហើយទៅ អត់យកឥវ៉ាន់ផ្ទះទៅទេ ទៅហ្នឹងទៅខ្លួនទទេ ។

ដាវ៉ា ៖ កាលនៅឃុំបន្ទាយដែក គេចាត់ឲ្យអ៊ំធ្វើអីវិញទៅ?

ស្រ៊ុន ៖ ខ្ញុំទៅនៅកន្លែងហ្នឹងខ្ញុំ គេប្រគល់គោមួយនឹម រទេះមួយ គោហើយនិងនង្គ័ល ភ្ជួរស្រែ ភ្ជួរដីហ្នឹង ភ្ជួរដីដាំពោត ដាំល្ពៅ ដាំសណ្តែកអីចឹងទៅតែប៉ុណ្ណឹង ។

ដាវ៉ា ៖ អ៊ំអាចភ្ជួរបានដែរនៅហ្នឹង បើអ៊ំធ្លាប់ទៅនៅភ្នំពេញ?

ស្រ៊ុន ៖ អូ! ថ្មីកមាំណាស់អូនរៀងគោ ខ្ញុំនៅអីស្រែតាំងពីប៉ុណ្ណឹងទៅ ដើរកាន់យាមនង្គ័លចេះហើយខ្ញុំភ្ជួរស្អាតទៀត គេមើលខ្ញុំទៀត គេមើលខ្ញុំ ព្រោះទី១ខ្ញុំស្រឡាញ់ការងារល្អ ភ្ជួរខ្ញុំកាន់ទប់នង្គ័លបានស្មើរត្រង់ស្អាតណាស់ ។

ដាវ៉ា ៖ ភ្ជួរតែ ភ្ជួររាស់រហូតទៅរយៈពេលដែលទៅនៅកៀនស្វាយទៅអ៊ំ?

ស្រ៊ុន ៖ ដល់ហើយថ្ងៃមួយដែលវៀតណាមចូលមកអូន គេដើរប្រាប់កាលហ្នឹងដូចជាម៉ោង១២ ស្អែកទៅប្រជុំនៅព្រៃកអាទាំង ថាអីចឹងទៅទាំងអស់គ្នា ព្រោះខែនេះរដូវរាំងរីងយើងវេចខោអាវឲ្យបានស្អាតការពារភ្លើងផ្សែង ហើយយើងទៅប្រជុំនៅព្រៃកអាទាំងម៉ោង៤-៥ព្រឹក ទៅទាំងអស់គ្នា ដល់ប្រជុំអីចឹងទៅ ព្រៃកអាទាំងនៅខាងត្បូងផ្លូវជាតិលេខ១ អូនអេ៎ ត្បូងផ្លូវជាតិលេខ១ ដល់ប្រជុំអីចឹងកងទ័ពវៀតណាមមកតាមផ្លូវមើលឃើញហ្នឹង ព្រោះប្រហែលពីហ្នឹងទៅផ្ទះ ។

ដាវ៉ា ៖ តាមផ្លូវជាតិហ្នឹង?

ស្រ៊ុន ៖ បាទ! តាមផ្លូវជាតិ ហើយស្រែកទៀតមៅបងប្អូនទៅមើលកូនៗមក ខ្មែរដែលមកជាមួយវៀតណាមហ្នឹងអ្នកស្រែក រួចហើយបានអ្នកយាម ពេលក្នុងអង្គប្រជុំអ្នកយាមអូនណា៎ អ្នកយាមពេលអង្គប្រជុំឃើញឡានមកអីចឹង បាញ់ បាញ់ដែរប្រាប់អ្នកដែលកំពុងខ្ទេសនាមឲ្យប្រជាជនស្តាប់ពេលហ្នឹង ដល់ហើយដឹងអីចឹងៗ បានថា ហ៎! រំសាយៗដែលប្រជុំពួកយើងទៅអីចឹងទៅ ទៅទល់អាផ្លូវជាតិយើងហ្នឹង នៅឈរចាំអីចឹងទំរាំឡានទៅអូន បាទ! ព្រោះឡាន ដូចថាឡាន៥មួយខ្សែអីចឹង ដឹកទៅផុតអីចឹង យើងឆ្លងទៅមកក្រោយទៀតអូនទៅផុតទៅមក ទៀតៗអីចឹង ។

ដាវ៉ា ៖ ដល់ពេលអីចឹងអ៊ំ ដល់ៗអ៊ំមកស្រុកភូមិវិញដែរ?

ស្រ៊ុន ៖ ខ្ញុំដូចកាលហ្នឹង ចង់នៅហ្នឹងម៉ង ខ្ញុំមកនៅមុខតាខ្មៅបានប៉ុន្មាន២យប់ អីពាយប់ ដូចជាវត្តក្រពើហារមុខតាខ្មៅអូនណា៎ មុននឹងមក ដល់ហើយស្ពានមុន្ទីរង្សយើងសុទ្ធតែក្រណាត់យើង

ពេញហ្នឹងទាំងអស់ ស្ពានមុន្នីវង្សយើងណាំអូន គេលីចេញពីនោះទៅហើយបែបមានគេឃាត់ មិនឲ្យយកចេញ ដើរលើក្រណាត់អូន ដើរមកតាមផ្លូវតាខ្មៅអីចឹងមក ទៅដល់ភូមិ ចូលដល់ភូមិ ដូចអត់បានចូលដល់ភូមិផងអូនហ៎ា គេជម្លៀសទៅទៀត ព្រោះអ្នកអស់ហ្នឹងដឹងថា វៀតណាមចូលមកក្រោយយើង យើងដឹងវៀតណាមចូលមុនអីចឹងហ៎ា គេជម្លៀសទៅទៀត ទៅនិងគេទៀតអូន ទៅនិងគេមួយគ្គារទៀត ។

ដារ៉ា : ដល់ណាទៅ?

ស្រ៊ុន : ខ្ញុំទៅមើលទៅត្រពាំងគល់ ត្រពាំងធំ អមលាំង អាលាក់កងដើង ស៊ីងឃៀច អីណាវត្តអន្គជុំណាណី ដើរមួយស្រឡាញ់ចូលខេត្តពោធិ៍សាត់ ។

ដារ៉ា : អូ?

ស្រ៊ុន : បាទ!

ដារ៉ា : ទៅហ្នឹងវិញទៀត?

ស្រ៊ុន : បាទ! ចុះបើគេទាញពីក្រោយជាប់ គេដាក់ពីក្រោយជាប់ កាលណាយើងនៅមិនទៅតាមគេ គេថាយើងនៅទទួលអាដែងដំណើរវៀតណាមនេះ អីចឹងទៀតអូន ។

ដារ៉ា : ទៅវេទនានៅហ្នឹងមួយសារទៀត?

ស្រ៊ុន : ទៅទៀត វែកទៀត ដល់វាដាច់ស្បៀងដាច់អី ខ្ញុំមកម្នាក់ឯង បងប្អូនខ្ញុំខ្លះមានអន់ចិត្តនឹងខ្ញុំខ្លះណាអូន គាត់ទៅណាទៅៗ ឈាមមួយជុំឯងចេះតែនឹកគាត់អីចឹង ចុះ៨-១០គ្រួសារនេះ ម៉េចវិញ ខ្ញុំមកម្នាក់ឯង ខ្ញុំចូលភ្នំពេញដំបូង ចូលភ្នំពេញៗ អត់មានអីនៅ ខ្ញុំចង់ចាក់មកផ្ទះវិញ មកដល់ក្រាំងជ័យហួសចោមចៅបន្តិចហ្នឹង ខ្ញុំនៅហ្នឹងបានជាជាងមួយអាទិត្យ មកដឹកឈើពីបឹងសាឡាងមុខពេទ្យរុស្ស៊ីយកទៅផ្ទះ ធ្វើតូបនៅហ្នឹងអូនណាំ ស្ងាត់គ្មានមនុស្ស ដល់ហើយហ្នឹងដល់ស្រុកហើយ ដល់ផ្ទះហើយ ដល់ផ្ទះអត់មានទាមទារដីក្នុងក្រុមសាមគ្គីក្នុងអីអត់ទេ ធ្លាប់នៅភ្នំពេញទៅភ្នំពេញទៀតហ្នឹង ទៅភ្នំពេញធ្វើឈ្មួញ ។

ដារ៉ា : ធ្វើឈ្មួញនៅភ្នំពេញ?

ស្រ៊ុន : ធ្វើឈ្មួញ មិនមែនឈ្មួញទេធ្វើកងការពារ ជុង ចន អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្នុងក្រៅប្រទេស ហើយ តាំង សារីម ប្រធាន ហើយ ជុង ចន អនុ ហ្នឹងអត់មានការងារសមរម្យធ្វើ ហើយឲ្យធ្វើនៃកកងការពារ ជុង ចន ហ្នឹងមកពីសព័រឡាន(អ្នកបើកឡាន) តាំង សារីម ហ្នឹងនៅស្រុកខ្ញុំទៅជាមួយគ្នា ផ្ដាំផ្ញើរគេទទួលទៅធ្វើៗបាន៥-៦ខែដែរកាលហ្នឹង ។ ខ្មែរយើងខុសពីគេអូន មិនថានេះ កានេសសង់ខ្ញុំប៉ុណ្ណឹងដែរ អូនឯងមើលឲ្យខ្ញុំរត់សំបុត្រក៏ខ្ញុំរត់ដែរ មិនគួរនិយាយទេអូន ពាពាមន្ទីរខ្ញុំយកសំបុត្រឲ្យទាំងអស់ ដឹងមកវិញប្រធានមន្ទីរសួរ តាៗ

ឯងមេចក៏ស្គាល់គេចែកគ្រប់ម៉្យេះ តាឯងយកសំបុត្រទៅចែកគេ ខ្ញុំថាខ្ញុំសុំសៀវភៅមួយទៀត ដើម្បីឲ្យថាហុចសំបុត្រឲ្យគេ ឲ្យគេស៊ីញ៉េទទួល ហុចសំបុត្រស៊ីញ៉េទទួល ប្រជុំថ្ងៃហ្នឹងយើងហុចសំបុត្រទៅជ្រុះបាត់សំបុត្រ គេថាមិនបានទទួលសំបុត្រពីយើងទេមិនខុស ខ្ញុំសុំអាហ្នឹងមួយទៀត ហៅការងារសន្តិសុខ រត់លិខិត ៣៣អគ្គភាពអូន ដល់បានមក ថ្ងៃក្រោយដូចជាគេវៃដាប់ឡូបែបដូចជាឃើតពេកខ្ញុំវៃ វៃៗដល់គេចែកវាមិនទាន់ ចុះ៣៣មន្ទីរនោះ ខ្ញុំថាឲ្យរកសង់ទឹមមកខ្ញុំវៃឲ្យ បានសង់ទឹមហើយវៃៗហើយ កាលហ្នឹងសំបូរណាស់របស់ប្រើណ៎អូន គេឲ្យយកម៉ាស៊ីនប៉ូវ៉េអូ រ៉ូណេអូសំរាប់ដាក់អូស ខ្ញុំធ្វើទៀតៗ ឧបមាថា៣០វៀបខ្ញុំទាញអាពងទាអាលេខស៊ីរ៉ូ មុនដំបូងយើងតំរង់អីចឹងដើម្បីឲ្យក្បាលវាត្រង់ ឬមិនត្រង់ វៀចឬមិនវៀច កាលណាត្រង់យើងមិនបាច់យកដល់លេខ៣០ទេ ...ហើយអីចឹងដែរ អូនឯងមើលខ្ញុំប្រាក់ខែ៩០ហ្នឹង ហើយអ្នកមួយនោះ គ្រាន់តែបោសគុ ហើយលើកទឹកតែឲ្យគេផឹកក្នុងហ្នឹងឡើង១១០ មួយរយដាងហើយខ្ញុំអត់ៗ ដល់ហើយកាលនៅហ្នឹង ខ្ញុំបើអូនធ្វើនៅហ្នឹងយូរបែបស្គាល់ដែរ ស ហូ វិញនៅជាមួយខ្ញុំប្រធានគយ ខ្ញុំហេងដែលអត់ចូលគយបើចូលគយប្រហែលស្លាប់ដែរ បើខ្ញុំសំបូរស្រីសំបូរអីពីមុន (សើច) ហើយ ស ហូ ទៅជាមួយខ្ញុំហើយកូនចេះតែ បន្ទោសខ្ញុំថាឪធ្វើការក្រោមរបបនៅតែល្ងមមិនព្រមលួតលាស់នឹងគេ គ្រាន់បើឪមិនចូលគយ គយមាន២៥នាក់ ហើយឲ្យជួយរើសបគ្រប់ឲ្យបានច្រើន ហើយដល់ហើយមុនដំបូង សុខ សុផល ប្រធានគយដល់ហើយ សុខ សុផល បែបគេរកអត់បាន គេមកធ្វើប្រធានមន្ទីរនៅក្រសួងពាណិជ្ជកម្មឲ្យ ស ហូ ទៅសម្មាទោសបើសិនជាបងប្អូនជាប់ខ្សែរយៈអីក៏កុំខឹងខ្ញុំ គាត់អត់សូវចេះទេ លឺតែគេប្រូកប្រ៉ាចគាត់ និយាយគាត់ ផឹកស៊ីទៅ គាត់អត់សូវចេះអូនណ៎ វប្បធម៌គាត់ទាប គេនិយាយសើច ធ្វើប្រជុំធ្វើអីចេះចុះគាត់និយាយអត់ចេញ តាំង សារីម ហៅទៅប្រាប់ថាមុននឹងនិយាយដាក់គេ យើងមើលទៅគេដូចសំរាមអីចឹងបានយើងនិយាយចេញ បើសិនជាស្មើរគ្នានិយាយអត់ចេញទេ ថាអីចឹង ដល់ស្រាប់ដល់សុតពីយុងក្រោមលែងទរអីចឹងមែន អ្នករាល់គ្នាដូចសំរាមអីចឹង អីចេះចុះបានមួយនៅក្បែរគ្នាកេះកុំនិយាយអីចឹង គាត់ប្រៀបធៀប(សើច) ខ្ញុំថាសើចៗ

ដារ៉ា : អន់ពេក?

ស្រ៊ុន : បាទ! ខ្ញុំថាសើច ស ហូ គាត់និយាយថាស៊ីណាត្រេ អាណិតគាត់ណាស់ ប៉ុន្តែគាត់ស្លាប់ហើយ តាហ្នឹងស៊ីនៅតែម្ដង ខ្ញុំទៅសុំអង្ករ ហេង សំរិន បាន៣តោន ខ្ញុំរាយការណ៍កម្មាភិបាលប៉ុន្មាន បុគ្គលិកប៉ុន្មាន កូនប៉ុន្មាន ប្រពន្ធប៉ុន្មាន សរុបទៅណា៣តោន ទៅដល់តាអង្ករសុំគេបាន តាឯងយក១តោន ខ្ញុំ១តោន ចែកគេតែ១តោនបានហើយ ខ្ញុំថាអត់កើតទេ

ព្រោះរបបទេ ខ្ញុំរាយការណ៍ទាំងអស់ហ្នឹង ដល់ធ្វើអីចឹងបងឯងនៅរួចខ្លួន ជាប់គុកខ្ញុំ (សើច) ឥលូវចែកគ្នាឲ្យគ្រប់ បើខុះចាំខ្ញុំសុំគេក្រោយកមកចែកទៀតទៅ ខ្ញុំអ្នកមុខការផារអីចឹងៗ ខ្ញុំខ្លាច ។

ដានី : ប្រពន្ធអ៊ំ ឈ្មោះអីគេ?

ស្រ៊ុន : ពីណាអូន?

ដារ៉ា : គ្រួសារ?

ស្រ៊ុន : អូ! កៅ សុផល ។

ដានី : កៅ សុផល?

ស្រ៊ុន : បាទ!

ដានី : ចុះឈ្មោះ មុំ ឈ្មោះក្រៅ?

ស្រ៊ុន : ហៅមុំ កៅ សុផល ហៅមុំ កៅ សុផល ឈ្មោះក្នុងបញ្ជីជាតិ ហៅក្រៅមុំៗ ។

ដារ៉ា : ហើយអ៊ំឈ្មោះហៅក្រៅឈ្មោះ ស៊ុម?

ស្រ៊ុន : ស៊ុម ហ្នឹងខ្ញុំដូរឈ្មោះ មុនដំបូង ស្រ៊ុនៗ ទៅ ស្រ៊ុន ទៅ ស៊ុម ។ ទៅពី ស៊ុម ទៅអាដែង មក ស្រ៊ុន វិញដូរឈ្មោះ៣-៤ ខ្លាចវាប់បេះតែដើរដូរ តែឥលូវពិតប្រាកដ ឥលូវហៅ សៅ ស្រ៊ុន ច្រើនជាងព្រោះខ្ញុំប្រើតាមបញ្ជីជាតិ សៅ ស្រ៊ុនៗ មិនងាយទេអូនដើរៗកុហក អូនឯងមើលមកពីតាំងគោក កាលហ្នឹងខ្ញុំនៅសខ្ពស់មើលទៅធំណាស់ ហើយវែកអីចឹង គេសួរ ថានៅឯណា ថានៅមកពីដើង ខ្ញុំអត់ដឹង សួរថាផ្លូវហ្នឹងទៅណា សួរគេ គេថាផ្លូវទៅ សៀមរាប អីចឹងបានហើយ ថាមកពីសៀមរាប គេសួរថាមកពីណា? ថាមកពីសៀមរាប បាទ! ថាមកពីសៀមរាប បើគេសួរណ៎អូន ត្រៀមទុក ហើយធ្វើការងារអី? ថាកាត់សក់ ខ្លាចគេសក់ វែងរកកាត់ អត់បេះកាត់ ខ្លាចកាត់ដេរ គេឃាត់ឲ្យនៅកាត់ដេរនៅក្នុងអគ្គភាព អត់កើត ថាបោកអ៊ុតទៅព្រោះធ្លាប់បោកអ៊ុត កុហកបោកអ៊ុត ប្រើអាហ្នឹងធ្វើកើតអូនណ៎ កុហកបានឆ្លើយ អីចឹងបានថា ។

ដារ៉ា : អីចឹងពួកខ្ញុំដូចអត់មានអីសួរអ៊ំទៀត ហើយអរគុណច្រើនដែលអ៊ំបានផ្តល់ព័ត៌មានអ៊ំ ។

ស្រ៊ុន : អរគុណណាស់ បានទំនាក់ទំនងល្អអីចឹង ខ្ញុំចូលចិត្តណាស់ ប៉ុណ្ណឹងបានយកទៅចាក់ផ្សាយ ។

ដានីៈ គាត់ថាចឹង?

ស្រ៊ុនៈ បាទ ។

ដានីៈ គាត់ថាម៉េច?

ស្រ៊ុនៈ បងឯងកាល៧៣អាតាំងវាមកយកមនុស្សពីផ្សារកាប់គោទៅ មិនព្រមទៅគេបើទៅនិងគេរួចខ្លួនហើយកាលហ្នឹង ។

ដានីៈ គាត់បន្ទោសអីចឹងដែរ?

ស្រ៊ុនៈ មានបន្ទោស ។

ដានីៈ កាលហ្នឹងអ៊ំទៅពីងគាត់ឲ្យជួយឬមួយយ៉ាងម៉េច?

ស្រ៊ុនៈ អត់ទេ កាលខ្ញុំមកនេះវាប្រាសស្រឡះហើយ គេថាមិនចង់ឲ្យមានបងប្អូនពាក់ព័ន្ធនៅខាងក្នុងចឹងណាអាអូនណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ អាហ្នឹងវាចឹងទេ បើដាច់ស្រឡះតែម្តងអាហ្នឹងចេះតែនេះហើយ បានខ្ញុំប្រាប់ថាអាអូនអើយ ។

ដានីៈ តែកាលដែលអ៊ំជាប់គុកអីហ្នឹងគាត់ជួយដែលឬអត់ទេ?

ស្រ៊ុនៈ អត់ទេ គ្រាន់ដឹងថាបងវាតែប៉ុណ្ណឹងទេ អត់មានទៅយកស្អីឲ្យអត់ទេ ថាមើលៗផងទៅបងពតអីប៉ុណ្ណឹងទេ បើថាយកអន្ករយកលុយអីអត់ទេ ឃើញផ្ញើឡាមទៅដែរ ឡាមកោពុកមាត់ហ្នឹងឃើញផ្ញើ៥ទៅដែរ ខ្ញុំកាលណាអត់កោវាស្រម៉ូមចឹងនឹកឃើញប្អូនដែរ ។

ដានីៈ តាមមើលគាត់អត់មានជួយអីទេ?

ស្រ៊ុនៈ អត់ទេ ។

ដានីៈ ចឹងអ៊ំធ្លាប់មានប្រសាសន៍ម្តាយអ៊ំក្នុងមួយខែពីរដងទៅកន្លែងគុកហ្នឹងដែរ?

ស្រ៊ុនៈ មកមើលគុកជាប់នៅតាកែវនេះ មកមើលអាពតវាជាប់គុកម៉ែខ្ញុំមកឃុំនៅហ្នឹង កាលហ្នឹងខ្ញុំនៅភ្នំពេញ ។

ដារ៉ាៈ នៅពេលរំដោះហើយ?

ស្រ៊ុនៈ បាទ!ខ្ញុំនៅភ្នំពេញ ។

ដារ៉ាៈ គាត់និយាយប្រាប់ដែលតើ?

ស្រ៊ុនៈ ខ្ញុំនៅភ្នំពេញកាលហ្នឹង ម៉ែមិនសមចឹងទេ ឥឡូវខ្ញុំផ្លាស់មកនៅខេត្តតែម្តងទៅក្រែងលោវាមានការចេះចុះទៀត អើល្មមៗយើងអប់រំគ្នានៅស្រុកនៅភូមិចឹងទៅ មិនបាច់បញ្ជូនវាព្រោះបងវាធ្វើការនៅនេះដែលចឹងទៅ ម៉ែខ្ញុំខានឃុំតាំងពីហ្នឹងមករហូត ។

ដានីៈ ចឹងមិនមែនកាលអ៊ំជាប់គុកជំនាន់ប៉ុល ពតហ្នឹងម្តាយទៅ?

ស្រ៊ុនៈ អត់ទេ មានខ្សែស្រូបអូនណាស់ ។

ដានីៈ ចឹងកាលជំនាន់ហ្នឹងគាត់អត់មានដែលជួយអីដល់គ្រួសារអ៊ំទេ?

ស្រ៊ុនៈ តែខោអាវមួយអត់ផង ។

ដានីៈ និយាយទៅគាត់ដាច់ខាតជាមួយបដិវត្តឬមួយយ៉ាងម៉េច?

ស្រ៊ុនៈ ដាច់ខាតជាមួយបដិវត្តមិនមែនដាច់ខាតជាមួយបងប្អូនទេ ធ្វើឲ្យត្រូវទឹសដៅរបស់គេណាអូនណា ។

ដានីៈ គេត្រូវធ្វើចឹង?

ស្រ៊ុនៈ បាទ!និយាយពីប្អូនខ្ញុំមួយនៅទេ ប្រុសតែបីទេ ក្នុងគ្រួសារហ្នឹងវាពៅគេ ពៅគេព្រោះអស់ត្រឹមវាហ្នឹងតែម្ដង ថ្ងៃហ្នឹងខ្ញុំអស់កំលាំងគេឲ្យរែកកណ្ដាប់ឆ្ងាយដល់ហើយខ្ញុំរែកបានបួនទៅប្រាំអំរែកឆ្ងាយដាក់អំរែកនិងមកផ្ទះ មកផ្ទះកំណើតមកដល់ឃើញម៉ែនៅហ្នឹងគាត់ដឹកស្រគូអាស្រគូតូចៗមិនមែនវែងៗទេ អាស្រគូកំណាត់ៗដល់ហើយខ្ញុំហែកស៊ីហូបខ្ញុំនិយាយត្រង់ហើយណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ ខ្ញុំហែកបានពីរប៉ុណ្ណឹងៗ គេមកពីណាគេថាបងអត់ធ្វើការទេ ខ្ញុំថាធ្វើហើយប្រញាប់ឈប់ម៉ើអស់កំលាំងណាអូន វាថាបងឯងតែមិនស្រួលខ្ញុំអត់ទុកឲ្យខូចបងប្អូនទេណាស់ ។

ដានីៈ គាត់ថាយ៉ាងម៉េច?

ស្រ៊ុនៈ ថាបងឯងតែមិនស្រួលខ្ញុំអត់ទុកទេ មិនទុកឲ្យខូចបងប្អូនទេ ដោយសារបងឯងមួយហ្នឹង ខ្ញុំស្ទុះទៅចង្រ្កានបាយយកពូថៅមួយ ថាឯងវ៉ៃអញចោលឯងបានធ្វើធំហើយឯងវ៉ៃទៅៗដល់ប៉ុណ្ណឹងអាអូនដាច់ខាត ។

ដានីៈ បាទ ។

ស្រ៊ុនៈ ដល់ហើយបានផ្ទះខាងលិចហ្នឹងបងឯងឡូឡាអី ខ្ញុំថាអត់មានឡូឡាអីទេ ខ្ញុំបាញ់ជួសយកពូថៅឲ្យវាវ៉ៃកុំឲ្យខូចកិត្តិយសវា កុំឲ្យអាប់អោនកិត្តិយសវាឲ្យវាឡើងធំទៅអាអូនណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ កាលមុននៅក្រសួងពាណិជ្ជកម្មឥឡូវឈប់ហើយ ។

ដានីៈ គាត់ធ្វើអីទៅណា?

ស្រ៊ុនៈ ធ្វើនៅក្រសួងពាណិជ្ជកម្មក្រៅប្រទេសនៅជាមួយឯកប៉ាងនេះ គាត់ដេរខាងកើតផ្សារថ្មីហ្នឹងណាស់ ឥឡូវឈប់ហើយ ។

ដានីៈ ឥឡូវគាត់នៅណា?

ស្រ៊ុនៈ នៅភ្នំពេញនោះ ។

ដានីៈ គាត់ឈ្មោះអី?

ស្រ៊ុនៈ ឈ្មោះ សោ ចំរើន កាលហ្នឹងនៅធ្វើការនៅខ័ណ្ឌ៧មករាដឹងខ័ណ្ឌអីនៅហ្នឹងដែរ ។

ដានីៈ ខណ្ឌ័៧មករា ។

ស្រ៊ុនៈ ចឹងណាស់អាអូន ។

ដារ៉ាៈ សោ ចំរើន?

ស្រ៊ុនៈ បាទ ។

ដារ៉ាៈ តែដោយសារតែសន្ដមហ្នឹងវា?

ស្រ៊ុនៈ វាចឹងវាដាច់ខាត ។

ដានីៈ កាលហ្នឹងគាត់ធ្វើអីដែលកាលជំនាន់បីឆ្នាំ?

ស្រ៊ុនៈ វាប្រធានក្រុមដែរ ។

ដានីៈ ប្រធានក្រុមនៅណា?

ស្រ៊ុនៈ នៅលិចអន្ដរកា ។

ដានីៈ នៅអន្ដរកា?

ស្រ៊ុនៈ បាទ ។

ដានីៈ ចឹងអឺពតគាត់មានធ្លាប់ស្ដីឲ្យអឺដែលអត់ ក្រៅពីគាត់ប្រទោសអឺកាលឆ្នាំ៧២-៧៣អាគាំងវាមកយកទៅ?

ស្រ៊ុនៈ បើទៅកាលហ្នឹងរួចខ្លួនហើយ ។

ដានីៈ តែក្រោយមកគាត់មានដែលបន្ទោសដែលស្ដីឲ្យទេ?

ស្រ៊ុនៈ អត់ទេ ។

ដានីៈ ចឹងប្អូនស្រីអឺមួយទៀតខ្ញុំធ្លាប់ជួបគាត់ម្ដងនៅខាងភ្នំព្រឹក្សណាស់ ឈ្មោះ សោ វ៉ាន់?

ស្រ៊ុនៈ វ៉ាននៅ ។

ដានីៈ ខ្ញុំធ្លាប់ជួបគាត់ដែលគាត់នៅលើភ្នំព្រឹក្ស ។

ស្រ៊ុនៈ ស្គាល់ដែរ?

ដានីៈ ស្គាល់ខ្ញុំធ្លាប់ទៅជួបគាត់ ។

ស្រ៊ុនៈ ចឹង?

ដានីៈ បាទ!គាត់ធ្វើអីដែលកាលជំនាន់ហ្នឹង?

ស្រ៊ុនៈ កាលហ្នឹងធ្វើទ័ពដែលឬពេទ្យមិនដឹងទេ ហើយប្ដីគេហ្នឹងប្រធានកងពលដែលមិនដឹងអាហៀង ខ្ញុំក្ដាប់មិនសូវបានដែរ ។

ដានីៈ បាទ!គាត់មានធ្លាប់មកលេងអីដែរ?

ស្រ៊ុនៈ មកដែលមកពីរដងអីដែលចឹង ។

ដានីៈ ចឹងវាងបងប្អូនអ៊ីមកដល់សព្វថ្ងៃមានការអន់ចិត្តគ្នាអីដែលអត់?

ស្រ៊ុនៈ អត់ទេ នឹកឃើញថាសង្គមដឹកនាំចឹងទៅហើយមានតែអរថែម អរថែមដូចម៉េចដូចថាវាចេះដឹកនាំឲ្យឃើញមុខគ្នាព្រឹកល្ងាចតាំងពីនោះមកដល់ឥឡូវនេះអរចឹងណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ ចឹងបានថាគេកាត់ទោសឌុចឥវ៉ាន់ថាត្រូវយកទៅកំទេចចេះចុះអ៊ីខ្ញុំថាអត់ត្រូវទេ បើទោះបីជាមានបងប្អូនក៏មិនថាដែរ ព្រោះឌុចឆ្លើយក្នុងតុលាការបើខ្ញុំមិនធ្វើតាមគេក៏បងប្អូនខ្ញុំមិនរស់ដែរ ។

ដានីៈ បាទ ។

ស្រ៊ុនៈ ចឹងគាត់ធ្វើដើម្បីម៉ែឪគាត់រស់ដែរ គ្មានពីណាចង់ធ្វើទេមួយៗឌុចកាឡេសង់ខ្ពស់ណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ ចឹងបានថាថ្នាក់លើទេ ថ្នាក់ក្រោមជាអ្នកអនុវត្ត ។

ដានីៈ ចឹងចំពោះអ៊ីៗយល់ឃើញយ៉ាងម៉េចដែលចំពោះមេដឹកនាំខ្មែរក្រហម យល់ឃើញយ៉ាងម៉េចដែរ ចិត្តអ៊ីផ្ទាល់វិញ?

ស្រ៊ុនៈ ខ្ញុំនិយាយខ្ញីមិនឲ្យវែងមកពីថ្នាក់ដឹកនាំរបស់យើងខុសហើយដើរខុសហើយបានជាចឹងវាមានជឿនលឿនកន្លែងណាបើវត្តអារាមវ៉ៃ បើវិហារវ៉ៃអស់ហើយជឿនលឿនដ៏យយោ! គ្មានរីកចំរើនទេ ធ្វើចេះតែធ្វើចឹងរីកចំរើនវាគ្មាន មកពីអ្នកដឹកនាំយើងដើរខុស ។

ដានីៈ ហើយឥឡូវហ្នឹងមានតុលាការហើយពួកគាត់បួននាក់នៅក្នុងតុលាការដែលគេកាត់ទោសគាត់ពល់ថ្ងៃហ្នឹងអ៊ីយល់ឃើញថាយ៉ាងម៉េចដែរ? យល់ឃើញថាការកាត់ទោសនិងត្រឹមត្រូវយុត្តិធម៌ឬក៏មិនយុត្តិធម៌ទេ?

ស្រ៊ុនៈ វាប៉ះនិយាយខ្ញីចឹងតែម្តងប៉ះ ប្អូនខ្ញុំបានប៉ុននិយាយវាថា តាអុងប៉ះតាឯកថាអាតាពែកប៉ះអាត្រង់ាលអាហ្នឹងវាគគ្នាសើច... ចឹងបានចេះតែទើនៅហ្នឹងចេះតែទុកៗស្នាទោសបើអស់មួយចឹងផុតទៅអស់មួយទៀតផុតទៅ ។

ដារ៉ាៈ ចឹងធ្វើឲ្យក្មេងជំនាន់ក្រោយអត់បានដឹងរឿងអីទាំងអស់?

ស្រ៊ុនៈ អត់បានដឹង ។

ដានីៈ វាកាប់ចោលទាំងអស់?

ស្រ៊ុនៈ កប់ចោល ។

ដារ៉ាៈ ហើយដល់ចឹងយើងរកពិសោធន៍ខុសត្រូវអីអត់កើត?

ស្រ៊ុនៈ ព្រោះខ្ញុំឮចេះ ខ្ញុំឮលោកហ៊ុន សែនណាប្អូនណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ សម្តេចសីហនុថាឲ្យយកទៅបូជាទៅ ហើយចាំដាក់ស្តូបអីមួយទៅព្រោះវាឆ្អឹងក្បាលនៅនេះហ្នឹងណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ លោកហ៊ុន សែនថាធ្វើចឹងអស់ភស្តុតាងហើយថាចឹង ។

ដានីៈ បាទ ។

ស្រ៊ុនៈ ហើយតា សីហនុត្រូវធ្វើចឹងហើយយើងចុះក្នុងក្រាំងក្នុងសៀវភៅទៅណាស់ បើខ្ញុំចង់ដឹងណាហ៊ានទៅសួរបើកមើលអូនណែសមិនចឹង ។

ដានីៈ បាទ ។

ស្រ៊ុនៈ បើនៅចឹងយើងដើរមើលឃើញៗមិនចឹងហើយកត់ក្នុងសៀវភៅណាហ៊ានទៅសួរបើកមើលអាហ្នឹងវាប៉ះពាល់ចឹងដែលហ្នឹងណាស់ សើច.... ។

ដានីៈ ខ្ញុំដូចជាអស់សំនួរអីហើយអ៊ឹមានអ៊ីចង់បន្ថែមដែលខ្ញុំមិនបានសួរអ៊ីទេ?

ស្រ៊ុនៈ ខ្ញុំដូចជាអត់មានអីទៀតទេអូនណាស់ ចេះតែខំប្រឹងទៅចេះខំធ្វើការឲ្យបានរីកចំរើនខ្ញុំស្គាល់ប្អូនឯងចេះជួយប្រាប់ចេះជួយណែនាំទៅអាអូនណាស់ ។

ដានីៈ បាទ ។

ស្រ៊ុនៈ យើងបត់បែនមិនទាន់គេវាមានគ្រោះថ្នាក់ កាលហ្នឹងខ្ញុំយ៉ាប់ណាស់ ចឹងបានថាជំនាន់ហ្នឹងអ្នកល្ងង់ឲ្យចាត់ការ កាលហ្នឹងប្អូនឯងទាន់ទេ ។

ដារ៉ាៈ អត់ទេ អ៊ឹ ។

ស្រ៊ុនៈ អត់ទាន់ទេ?

ដារ៉ាៈ បាទ ។

ស្រ៊ុនៈ អ្នកល្ងង់ឲ្យចាត់ការអ្នកមានប្រាជ្ញាឲ្យរែកអាចម៍នោមខ្ញុំរែកអាចម៍ធុងជ័របូប្អូនទាក់ ។

ដានីៈ ចឹងអ្នកល្ងង់ឲ្យធ្វើអ្នកដឹកនាំ?

ស្រ៊ុនៈ អ្នកល្ងង់ឲ្យចាត់ការអ្នកមានប្រាជ្ញាឲ្យរែកអាចម៍រែកទឹកនោមអូនឯងមើលនិយាយពីមួយខែហូបពីរដងក្នុងរោងបាយមួយៗហ្នឹងណាស់ ហើយថាសវាដាក់លាមួកដល់មួយខែពីរដងវាហៀមាត់ចឹងវាហៀកំពស់នេះអូន ។

ដានីៈ បាទ ។

ស្រ៊ុនៈ ខ្ញុំធ្លាប់យកស្លឹកចេកទៅដាក់មាត់ពាងសឹកដៃចេះ យើងអោបចាក់ដាក់ធុងរែក ។

ដានី:		បាទ ។

ស្រ៊ុនៈ		មានពីរបីសារហើយវាកំពស់ហ្នឹងអត់ហ៊ានចូកអត់ហ៊ានកាប់សុខចិត្តអោបដាក់តិចៗ ទៅណាស់ ។

ដាវ៉ាៈ		បាទ! ខ្លាចកំពប់ ។

ស្រ៊ុនៈ		មានអីគ្រាន់តែផ្អៀងអានោះបាក់មួយកំណាត់ប្រាវខ្ទាតមករូពេញមុខពេញមាត់ខាងណាមក អាហ្នឹងធ្វើតែម្ដងវីបៗ រែកបណ្ដើរគិតបណ្ដើរគេប្រើឲ្យអស់គេឲ្យរែកអាចម៍រែកនោមហើយ នោមដាក់កង់តាមភ្លឺស្រែឲ្យរែកនៅហ្នឹងទៀត ទឹកនោមរែកនៅនិងទៀតទឹកនោមរែកនៅហ្នឹង ទៀតយកមកធ្វើដីលេខ១ ទៀតនិងណាស់ ។

ដាវ៉ាៈ		អត់ឲ្យនោមចោលទេ?

ស្រ៊ុនៈ		អត់ឲ្យនោមចោលទេ ឲ្យយើងនោមដាក់ពាង ។

ដានី:		បាទ! អរគុណអ៊ំច្រើន ។

ស្រ៊ុនៈ		បាទ ។

**ចប់**